## វគ្គទី១

## អ្នកគ្រូម៉ូឌែល

សម្លឹង បង្អួសពីសរសៃសក់ទន់ភ្លន់ដែលកំពុងប្រលែង លេងលើបរិវេណដើមទ្រូងពណ៌ឈ្លូក ខ្ចី អ្នកស្រីកុលាបលេបទឹកមាត់ក្អឹកចំពោះការប្រឈមភ្នែកនឹងបបូរមាត់ស្រស់ដូចសេកសោម ដែលប្រែទៅជាក្រហមប្រឿងៗនៅចំពោះមុខ។

"ស្អាតម្លឹងៗ បើលក់មិនចេញ មិន ដឹងធ្វើមេអណ្តើកបានការអីទេ"គាត់និយាយប្រាប់ខ្លួនឯង។

មើលទៅដៃខាងស្តាំរបស់នាងដែលកំពុងកាន់ដងវ៉ែនតាធំខ្មៅទម្លាក់ចោលលើគល់ភ្លៅស រលោង  អ្នកស្រីកុលាបដឹងថា ទោះយ៉ាងណាថ្ងៃនេះ ម្ចាស់រាងកាយ នេះត្រូវតែនាំនូវលាភស ក្ការៈមកអោយគាត់ដោយខាងមិនបាន។ម្ល៉ោះហើយទោះបីជាផែនថ្ពាល់សស្លាំងនិងពន្លឺ ភ្នែក ដែលប្រែទៅជាមុត ថ្លាបានអោយសញ្ញាថា នារីរាង រាវនៅពីមុខខ្លួននេះកំពុងបៀមទុកនូវទោ សៈក៏ស្ត្រីអ្នករកស៊ីជួញដូរមនុស្សនៅតែមិនបោះបង់ចោលការព្យាយាមៈ

ម្តងនេះ លុយច្រើនណាស់ណ៎ា? មានទៅពិបាកអី លុយបានមកដោយស្រួល មិនខ្វះទេអ្នក ចង់បានដូចឯងប៉ុន្តែគេ វាគ្មានឱកាសកុំបាច់ធ្វើឫកពេកអី គ្មានអ្នកណាដឹងទេ ដឹងតែយើងពីរ នាក់គត់ ធានាថាជិត!

ធីតាស្រួបដង្ហើមវែងបង្ហាញថានាងកំពុងសង្កត់ចិត្តអត់ទ្រាំចំពោះភ្លើងកំហឹងនិងភាពតានតឹ ង។នាងឈ្ងោកមុខមិនចេញស្តី តែចិញ្ចើមនាងដែលជ្រួញចូលគ្នានិងបបូរមាត់ដែលខាំស្ទើរ ដាច់ហាក់ជាចម្លើយស្រេចហើយថា អ្នកបញ្ចុះបញ្ចូលគួរតែក្រោកចេញ។ប៉ុន្តែនាងក៏គួរស្គាល់ ចរិតម៉ែកុលាបដែរ។តើមានស្រីស្អាតណាដែលមិនចុះចាញ់ក្រោមការបញ្ចុះបញ្ចូលរបស់គាត់ ប្រសិនគាត់ចង់បានហើយនោះ?។

ស្ត្រីសក់ពណ៌លឿងទុំនិយាយបន្ត នៅពេលចាប់អារម្មណ៍ថាឱកាសនៅហុចអោយនៅឡើយ ៖

ណ៎ា!ណ៎ាឪម៉ា!ណ៎ាកូន!?អូខេSweeties?អូខេ ណ៎ា?មីងធានាមីងរៀបចំអោយ!រុយមួយក៏ មិនអោយដឹងដែរ!ធានាថាស្ងាត់!

ឌីម៉ា DeeMaអ្នកគ្រូបង្ហាញម៉ូតដ៏មានកេរ្តិ៍ឈ្មោះនៃក្រុមKanary Fashion ទទួលស្គាល់ថានាងមិនអាចបន្តរក្សាភាពស្ងៀមស្ងាត់តទៅទៀតទេប្រសិនបើ ចង់អោយស្ត្រីល្មោភប្រាក់ នេះបញ្ចប់ ការព្យាយាមរបស់គាត់។

នារីងើបមុខចោលពន្លឺភ្នែកក្នុងន័យអង្វរករទៅ រកគាត់មុនពេលបង្ហើរ ប្រយោគតបៈ

មីង...

ស្ត្រីចំណាស់ប្រកបរបរជាមេអណ្ដើកហាក់មិនព្រមអោយនាងបញ្ចប់ប្រយោគទាន់ទេ គាត់លើកបាតដៃទាំងសង មកទ្រអង្កែលវង់ភក្ត្រដែលមានរង្វង់ពងក្រពើសមឥតទាស់នៅចំពោះមុខ៖

ស្រីស្អាតបំផុតរបស់មីង!អ្នកណាឃើញនាងហើយមិនឆ្កួតចិត្តនោះឌីម៉ា?

កញ្ញាបិទភ្នែកដកដង្ហើមយូរទាំងទើសចិត្ត។តែគំនិតមួយលេចឡើងក្នុងចិត្តនាង៖

ទាល់តែមានចរិតដូចគាត់ បានជា គាត់រើសយករបរនេះទៅកើត!

គិតហើយនាងមិនរវល់នឹងអាកប្បកិរិយាពោរពេញដោយល្បិចកលនេះទៀតទេ។នាងរុញ ដៃគាត់ទម្លាក់ចេញថ្នមៗរួចនិយាយមួយៗ៖

មីង!ខ្ញុំអរគុណណាស់!អត់ចង់អោយមីងខាតពេលជាមួយខ្ញុំទេ!និយាយត្រង់ទៅ!គឺអត់ទេមីង! មីងរកគេផ្សេងទេ!ខ្ញុំត្រូវចេញទៅសិនហើយ!

នាងស្ទុះក្រោកទន្ទឹមនឹងការបញ្ចប់ឃ្លាបដិសេធទន់ភ្លន់តែសោះអង្គើយនេះ។ឌីម៉ាប្រញាប់ ដើរអោយញាប់ក្នុងពេលចាប់អារម្មណ៍ថានៅសាឡុងផ្សេងៗនៃបន្ទប់VIPរបស់ភោជនីយដ្ឋាននេះមានវត្តមានមនុស្សជាច្រើនទៀត។ប៉ុន្តែពាក្យស៊កសៀតពេបជ្រាយស្រាលៗរបស់ស្ត្រីឈ្មោះកុលាបបានបង្អាក់ដំណើរនាង៖

ចាំបាច់ធ្វើគ្រាន់អី!?ធ្វើមើលតែមិនដែលអញ្ចឹង!

ឌីម៉ានៅទ្រឹងហើយងងឹតឈឹងក្នុងអារម្មណ៍។ធីតាយើងលើកវ៉ែនតាមកបិទបាំងវង់ភក្ត្រដែលកំពុងរងរំខានដោយវិបត្តិ។នាងមកកាន់កោះ បាលីពេលនេះគឺមានបេសកកម្មនាំក្រុមកិន្នរីហ្វេសហ្សិនរបស់ខ្លួនមកចូលរួមជាមួយការបង្ហាញម៉ូតAsia Garden សម្រប់បុប្ផាអាស៊ីដែលជា

គោលដៅទស្សនាកម្សាន្តនៃអភិជននានាមកពីគ្រប់ទិសទី។នៅពេលដែលនាងបានទទួលការណាត់ អ្នកស្រីកុលាបមកកាន់ភោជនីយដ្ឋានលំដាប់លេខមួយ នៃដែនកោះដ៏ល្បីបណ្ដាច់របស់ឆ្នេរJavaនេះនាងអាចទាយដឹងមុនហើយថា គាត់កំពុងចង់បានអ្វី។

នាងបែរក្រោយនិយាយទៅកាន់គាត់ដោយទឹក មុខស្មើះ

មីង!ខ្ញុំអត់ប្រកាន់មីងទេ!តែសូមមីងគោរពខ្ញុំខ្លះ!ដោយសារខ្ញុំនៅរាប់អានមីង បានជាខ្ញុំមកជួប!មីងយល់ចិត្តខ្ញុំផង!

ស្ត្រី នោះមិនព្រមអន់ទេ។នៅពេលគិតថាត្រីព្រមមិនស៊ីសន្ទូច គាត់បែរជាដំឡើងសំឡេងដោយទោមនស្សះ

មកពីឯងឌីម៉ា!ឯងបានល្បីតិចតួចចង់មកលេងឫកដាក់មីងធ្វើអី?ឯងដឹងទម្លាប់ធ្វើមនុស្សក្រឡិចក្រឡុកផ្លាស់សម្ដីចុះឡើងរបៀបឯង ខូចប្រយោជន៍គេប៉ុន្មាននាក់ទេ?

ភាពក្រៀមក្រំហើរចេញតាមក្រសែភ្នែកនារីរូប ល្អ។ជាទម្លាប់នាងមិនចូលចិត្តនិយាយច្រើនទេ តែបំណាចនឹងមានការយល់ខុស នាងចាំបាច់ត្រូវតែបកស្រាយ។នាងថយមកអង្គុយសម្លឹងគាត់។សម្រួលចិត្តបន្តិចទើបនាងពោលពន្យល់៖

បាន!ខ្ញុំនិយាយអោយវាជ្រះស្រឡះតែម្ដងទៅអញ្ចឹង។មីង!កាលណឹងប្អូនខ្ញុំឈឺ!ខ្ញុំត្រូវការលុយ!ខ្ញុំអស់លទ្ធភាពក្នុងការជួយវា!បានជា...តែខ្ញុំអត់បានប្រាប់មីងថា...ខ្ញុំនឹងធ្វើរឿងហ្នឹងរហូតទេ....!ខ្ញុំអរគុណមីង!កាលណោះបានមីងជួយខ្ញុំ...មិនអញ្ចឹងប្អូនខ្ញុំមុខតែស្លាប់ហើយ...តែមីងធ្លាប់លឺខ្ញុំប្រាប់ហើយមែនទេ... ខ្ញុំគ្មានថ្ងៃធ្វើអញ្ចឹងទៀតទេ។

នៅពេលស្ត្រីចំណាស់ពេបមាត់ងាកមុខ ចេញបញ្ចោះបន្សោក។ឌីម៉ាពន្យល់បន្ថែម៖

ខ្ញុំមកបាលី... មីងដឹងហើយសិស្សខ្ញុំគេនឹងចូលរួមក្នុងAsia Garden ។ហោចណាស់ក៏មានចំណែកតូចមួយសម្រាប់កិត្តិយសស្ត្រីខ្មែរដែរ... ខ្ញុំអត់ធ្វើរឿងប្រមាថខ្លួនឯង... ប្រមាថកិត្តិយសប្រទេសទេ... !...

នាងញញឹមស្ងួតដាក់គាត់រួចក្រោកចេញជាលើកទី២។តែស្ត្រីចំណាស់រហ័សជាង... គាត់ស្ទុះចាប់ដៃនាងជាប់...។

ឪម៉ាជ្រួញចិញ្ចើមសឹងដល់គ្នា...នាងងាកសម្លឹងជុំវិញខ្លួន...ទីនេះជាភោជនីយដ្ឋានជាន់ខ្ពស់បំផុតសម្រាប់កោះបាលីទាំងមូល។ហើយបណ្តាជន ដែលកំពុងមានវត្តមាននៅទីនេះ អាចចាត់ជាស្រទាប់មនុស្សមានប្រាក់កំពូលៗមកពីបណ្តាប្រទេសផ្សេងៗដើម្បីចូលរួមក្នុងទិវាបង្ហាញម៉ូតបុប្ផាអាស៊ី នាងមិនចង់ឲ្យកាយវិការខ្លួនមានភាពឆ្គាំឆ្គង នៅចំពោះមុខជនបរទេសទាំងនោះឡើយ ម្ល៉ោះហើយទើបស្រស់ស្រី ខំសង្កត់ចិត្ត នៅឈរទ្រឹងសម្លឹងមុខស្ត្រីល្មោភប្រាក់។ ជាមួយនឹងម្រាមដៃទន់ល្វក់ ដែលឈោងដោះវ៉ែនតាចេញពីភ្នែកបូករួមនិងផ្ទៃមុខស្មើថៃសរបស់នាងហាក់បង្កប់នូវសំណួរទៅកាន់អ្នកស្រីកូឡាបជាស្រេចហើយថា "តើចង់យ៉ាងម៉េចទៀត ?"

អ្នកស្រីកុលាបសម្រួលឥរិយាបថឱនមកខ្សឹបក្បែរត្រចៀកធីតារូបស្អាតទាំងអាកប្បកិរិយាឥតអៀនខ្មាស៖

ឪម៉ា!ភ្ញៀវនេះជាសាសន៍យើងទេកូន!... ថានគេខ្ពស់កប់ពពកហើយនៅក្មេងទៀត !...

អ្នកគ្រូម៉ូដែលនៅទ្រឹង តែចិត្តកំពុងឈឺចាប់។នាងដឹងថាស្ត្រីមេអណ្តើកល្មោភប្រាក់នេះ ហ៊ានប្រមាថខ្លួនម្តងជាពីរដងបែបនេះក៏ព្រោះនាងធ្លាប់ លក់ខ្លួនដើម្បីប្តូរយកប្រាក់មកព្យាបាលជំងឺប្អូន។

ជាមួយអតីតកាលដែលបានកន្លងទៅប៉ុន្មានខែហើយប៉ុន្តែនៅតែជាសុបិនអាក្រក់ដែលតាមមកលងបន្លាចនាងជានិច្ចកាល ប្រៀបបានទៅនឹងស្រមោលអសោចដែលខំលុបលាងមិនចេះជ្រះនេះធ្វើអាយនាងអាចបានត្រឹមប្រាប់ខ្លួនឯងថា នេះហើយដែលចាស់លោកថា ទូកទៅកំពង់នៅ។

ចំណែកស្ត្រីកុលាបព្រោះតែអាងលេសនេះហើយដែលខំតាមឪម៉ា តាំងពីភ្នំពេញរហូតដល់កោះចុងបង្អស់នៃឆ្នេរសមុទ្រចារ៉ារបស់ឥណ្ឌូណេស៊ី។គាត់ដឹងច្បាស់ថា... ផ្កាមួយទងនេះនៅតែជា ប្រយោជន៍លើសលុបសម្រាប់គាត់នៅឡើយ...។

ក្នុងមួយខណៈ ដែលតរុណីយើងនៅទ្រឹង ដោយភាពឆ្អែតចិត្តសូរស័ព្ទក្រអៅមួយលាន់ខ្ទរផ្ទៃបន្ទប់ភោជនីយដ្ឋានទាំងមូល...

ជម្រាបសួរ មីងកុលាប ?...

ចង់មិនចង់ ឪម៉ាត្រូវតែងើបមុខសម្លឹងទៅរកម្ចាស់សូរស័ព្ទ ដែលនាងចាប់អារម្មណ៍ថា ពោរពេញដោយអំនួត និង ភាពច្រឡើសបើស... ។

នុ៎ះហ្ន៎...

បុរសក្មេងវ័យមានអាយុមិនលើសពី ៣០ឆ្នាំឡើយ បើតាមស្មានកំពុងដើរមួយៗសំដៅមកដោយមានក្រុមកងការពារសន្ធឹកសន្ធាប់ហែហមមកពីក្រោយផង។គ្រាន់តែឃើញដំណើរពើងទ្រូងរបស់ជននេះក៏តរុណីអាចដឹងជាមុនថា អ្នកដែលទើបបង្ហាញខ្លួនមិនមែនជាមនុស្សគួរអោយរាប់អានដែរ។ស្រាប់តែរំពេចនោះ អ្នកស្រីកុលាបឈ្ងោកមកខ្សឹបដាក់ត្រចៀកស្រស់ស្រីជាលើកទីពីរ ៖

ម្នាក់ហ្នឹងហើយឪម៉ា !.អ្នកប្រុស សិទ្ធិគុណ កូនលោកឧកញ៉ា ឆាយ៉ាណគុណ?...

ឆាយ៉ាណគុណ បុរសថៃដែលមានអំណាចក្នុងចង្កោមអ្នកសេដ្ឋកិច្ចខ្មែរ រឿងអីថាឪម៉ាមិនធ្លាប់ដឹងមិនធ្លាប់លឺនោះ នាងថែមទាំងដឹងទៀតថា ជននោះមានភរិយាជាជនជាតិខ្មែរ ហើយមានកូនប្រុសតែមួយគត់ គឺលោក សិទ្ធិគុណ នេះឯង។

ថៅកែក្មេង សិទ្ធិគុណ មានគេឯងស្គាល់ច្រើន មិនមែនអាស្រ័យដោយគុណភាពនៃការដឹកនាំជំនួញដូចឪពុកខ្លួនទេតែមនុស្សភាគច្រើនស្គាល់គេដោយសារតែ អំពើច្រឡោងខាមដ៏ល្បីល្បាញនោះទៅវិញ... ។

ស្រីស្រស់ទុកថាខ្លួនមានសំណាងអាក្រក់ហើយដែលបានជួបជននេះនាងរលាស់ដៃចេញពីអ្នកស្រីកុលាបហើយវាចាដោយផ្ទៃវង្សភក្តិស្លូតថែស ៖

ប៉ុណ្ណឹងចុះមីង !ខ្ញុំមានរវល់ផ្សេងទៀត.!

តរុណីដើរចាកចេញយ៉ាងរហ័សក្នុងចេតនាចង់គេចចេញឲ្យផុតពីមនុស្សដែលទើបនឹងមកដល់ ប៉ុន្តែនាយសិទ្ធិគុណហាក់ដូចជាបានត្រៀមទុកជាមុនរួចហើយ...គេស្ទុះមកពាំងពីមុខតរុណីរូបស្រស់...។

ឪម៉ាសែនតឹងចិត្តជាមួយនឹងក្រសៃភ្នែកច្រឡើសបើសដែលជនម្នាក់នោះផ្តោតសម្លឹងរាងកាយនាងពីលើដល់ក្រោមហាក់គ្មានរអែងចិត្តនិងខ្វះសីលធម៌ជាសុភាពបុរស។សំឡេងគេលាន់ឡើងលាយឡំជាមួយនឹងស្នូរជញ្ជក់មាត់ ៖

អ្នកគ្រូឪម៉ាស្អាតជាងពាក្យគេល្បីទៀត..!...លើកនេះមានត្រៀមឈុតប៊ីគីនីមកដេរម៉ូតទេ?...ខ្ញុំនឹងទះដៃឲ្យពីរោះជាងគេទាំងអស់នៅលើកោះបាលីនេះ !...

នៅពេលប្រុសម្នាក់ប្រាថ្នាយកប្រាក់មកដេញថ្លៃនាងសម្រាប់កំដរអារម្មណ៍ ការមើលស្រាលបានបង្ហាញចេញស្រេចទៅ ហើយប៉ុន្តែវាមិន ស្មើនឹងសកម្មភាពមិនអោយតម្លៃកណ្តាលចំណោមដូច្នេះឡើយ។ឪម៉ាអាចធ្វើអ្វីបានក្រៅពី ងាកមុខចេញទាំងភ្នែកក្រហម។នាងក្រមុំឈានបង្ហួសដំណើរចាកចេញដោយគ្មានតបត... តែនាយ សិទ្ធិគុណ មិនបានអនុញ្ញាតអោយអ្វីៗដំណើរការស្រួលដល់ម្លឹងទេ គេស្រវាចាប់ដៃស្រស់ស្រីជាប់ទាំងមាត់ទំពាស្ករកៅស៊ូញ៉ាច់ៗ ។

អ្នកគ្រូវ័យក្មេងប្រឹងរលាស់ដៃចេញទាំងភ័យតក្កមា...ល្មមពេលក្រសែភ្នែកជាច្រើនក្នុងភោជនីយដ្ឋាន សម្លឹងមកដោយក្តីភ្ញាក់ផ្អើលនិងងឿងឆ្ងល់។អ្នកចាត់ការនៃភោជនីយដ្ឋានជាន់ខ្ពស់នេះរត់ចូលមកក្បែរសិទ្ធិគុណដោយកាយវិការត្រុនៗ...ភាសាអង់គ្លេសរបស់គេពោលឡើងទាំងរញ៉េរញ៉ៃនូវពាក្យប៉ុន្មានម៉ាត់ថា ៖

សូមមេត្តាកុំបង្កភាពចលាចលទាន !...

គ្រាន់តែឃើញកាយវិការអ្នកចាត់ការរូបនេះ ក៏អាចដឹងថា គេធ្លាប់ស្គាល់ សិទ្ធិគុណ និងដឹងអំពីទង្វើរបស់ពាណិជ្ជករក្មេងនេះច្បាស់ណាស់... ព្រោះនៅរាល់ឆ្នាំ... ក្នុងទិវាសម្រស់បុប្ផាអាស៊ី មិនដែលថាគ្មានវត្តមាននាយ សិទ្ធិគុណ លើកោះបាលី ម្តងណាឡើយ... ។

ប៉ុន្តែលើកនេះមិនត្រឹមតែត្រូវរញ៉េរញ៉ៃទេនាយចាត់ការភោជនីយដ្ឋានទៅជាគាំងចលនានៅពេល ដែលអភិជនវ័យក្មេងសិទ្ធិគុណប្រើម្រាមពីរភ្ជង់តម្រង់ក្បាលគាត់ដូចជាកាយវិការប្រើកាំភ្លើងរបស់ពួក អ្នកលេងក្នុងភាពយន្តហូលីវូដ។

ឪម៉ា ឃើញភ្ញៀវទេសចរខ្លះងាកមុខចេញដោយមិនពេញចិត្ត ខ្លះទៀតតាមដានបន្តក្នុងភាពរិះគន់។បរិវារហែហមពីរ នាក់របស់បុរសអភិជន ខ្មែរដើរមក រកនាយចាត់ការដោយស៊កប្រាក់មួយសំណុំទៅ ក្នុងហោប៉ៅគាត់ព្រមទាំងកៀងបណ្តើរគាត់អោយចាកចេញផង។បុរស នោះលើកដៃជូតញើសក្បាលហើយចាកចេញទៅដោយទឹកមុខស្ងួត។

ឱម៉ាងាកទៅ រកជំនួយពីអ្នកស្រីកុលាបឃើញស្ត្រីរូបនោះធ្វើមុខមាំទាំផ្ដើនមករកនាងជាសញ្ញាថានាងមិនចេះប្រមាណខ្លួនសមនឹងទទួលលទ្ធផលបែបនេះ។មិនត្រឹមតែប៉ុណ្ណឹងទេ គាត់ថែមទាំងលូក មាត់ពោលបញ្ជិតបញ្ជៀង៖

"តា ប៊ិនាយកហ្នឹងដូចភ្លេចគិតថា ឧកញ៉ាឆាយណគុណជាម្ចាស់ភាគហ៊ុនធំនៅហាងនេះអញ្ចឹង"។

ឱម៉ាភ្ញាក់ខ្លួនព្រើត... នាងទើបនឹងដឹងខ្លួនថា... ទីនេះជាកន្លែងអ្នកណាហើយហេតុអ្វីបានជាអ្នកស្រីកុលាបសម្រេចណាត់នាងមកកាន់កន្លែងនេះ។នាងទោមនស្សកាន់តែខ្លាំងដោយសួរខ្លួនឯងថា តើបេះដូងស្ត្រី នោះធ្វើមកពីអ្វីបានជាគាត់ដាច់ចិត្តបោះបង់ចោលស្ត្រីភេទទន់ខ្សោយដូចគ្នាអោយនៅរងគ្រោះកណ្ដាលចំណោមបែបនេះ។

អ្វីៗនៅក្នុងកណ្ដាប់ដៃគេទាំងអស់ អញ្ចឹងហើយបានជាបុរសក្មេងនេះក្អេងក្អាងដល់ម្លឹង។ប៉ុន្តែទោះជាយ៉ាងណាក្ដី ក៏នាងនៅតែព្យាយាមរលាស់ដៃចេញពី ប្រអប់ដៃបុរសគួរឲ្យស្អប់ខ្ពើមនេះពេញទំហឹងម្ដងហើយម្ដងទៀត។ទីបំផុត... គេលែងដៃនាង.... ប៉ុន្តែនៅតែពោលមកកាន់នាងទាំងងងើល ៖

ជួបគ្នាហើយ... នៅបាយជាមួយគ្នាមួយពេលសិនមិនបាន? !...

ឱម៉ាឥតចេញស្ដីមួយម៉ាត់។នេះជាទម្លាប់របស់នាង បន្ថែមពីនោះនាងដើរចាកចេញយ៉ាងលឿនតម្រង់មាត់ទ្វារភោជនីយដ្ឋាន... ទាំងត្រចៀកស្ដាប់លឺសំឡេងហៅរញ៊ីរញ៉ូវ របស់អ្នកស្រីកុលាបពីក្រោយខ្នង...

ឱម៉ា!...ឈប់... ឈប់សិន !...

តរុណីកេត ឱម៉ាគ្រូបង្ហាញម៉ូតដ៏មានឈ្មោះល្បី ដោយសារតែរូបសម្ផស្សស្រស់ស្អាត ដូចទេពធីតាក្នុងរឿងព្រេងនេះ ប្រាកដក្នុងចិត្តហើយថា អ្នកស្រីកុលាបខ្លាចបុណ្យសិទ្ធិគុណ ព្រមទាំងចង់បានប្រាក់រង្វាន់ពីគេផង បានជាស្ម័គ្រចិត្តចូលមកបញ្ចុះបញ្ចូលនាង ឲ្យទៅធ្វើជាស្រីបម្រើសិទ្ធិគុណ។គិតដល់រឿងនេះពេលណាកាន់តែមួហ្មងណាស់...កាលបើលឺសំឡេងស្រែកហៅរបស់អ្នកស្រីកុលាប នាងរឹតតែប្រឹងដើរញាប់ជើងជាងមុន...តែស្នូរផាំងខ្លាយបានធ្វើឲ្យជំហាននាងឈប់ទ្រឹងវិញដោយស្វ័យប្រវត្តិ...។

ឌីម៉ានៅទ្រឹងលែងដើរទៅមុខរួច...តែនាងមិនបែរក្រោយទេ...មនុស្សម្នារួមទាំងអ្នកបម្រើ និងអ្នកចាត់ការដែលនៅសេសសល់រត់ចេញទៅក្រៅបន្តបន្ទាប់គ្នា... ល្មមពេលនារីយើងឃើញអំបែងកែវចានរួមជាមួយចាសលើកម្ហូបខ្ទាតខ្ទាយរសាត់មកក្បែរៗជើងនាង។

សំឡេង សិទ្ធិគុណ លាន់ឡើងយ៉ាងក្រអឺតពីក្រោយខ្នង... ៖

បើនាងហ៊ានឈានតែមួយជំហានទៀត... កុំស្តាយក្រោយកេតឌីម៉ា !...

អ្នករត់ តុដែលត្រូវបានសិទ្ធិគុណទាញគ្រវែងថាស អាហារបោកកំចាយបង្កភាពភ្ញាក់ផ្អើលអំបាញ់មិញប្រុងនឹងអោនរើសសំអាតប្រដាប់ប្រដាមកវិញដែរតែការសំឡុតចុងក្រោយរបស់អ្នកមានវ័យក្មេងលាន់ មកដាច់ ណាត់ពេកធ្វើអោយគេត្រូវដូរ ចិត្តដកថយចោល ការងារកណ្តាលទីចេញទៅក្រៅបាត់តាមអ្នកមុនៗដែរ។

ភាគទី២

ឌីម៉ាមិនខុសពីស្ត្រីភេទទន់ខ្សោយដ៏ទៃទៀតទេ... នាងឆាប់តក់ស្លុត... ឆាប់ភិតភ័យ... ឆាប់រំជួលចិត្ត... តែវត្ថុម្យ៉ាងដែលនាងមានលើសពីស្ត្រីនានានោះគឺនាងក៏ចិត្តរឹងណាស់ដែរ។វាលំបាកក្នុងការលួងអង្វរបុរសដែលគ្មានសីលធម៌របៀបនេះ តែវារឹតតែលំបាកជាងស្លាប់ទៅទៀតក្នុងការលុះតាមបំណងគេ។

ឌីម៉ាឈានជើងបន្តទៅមុខទាំងទឹកភ្នែកស្រក់រមៀល។បេះដូងនាងលោតយ៉ាងញាប់អ្វីដែលកល្យាណីនឹកឃើញក្នុងពេលនេះ មានតែម្យ៉ាងគត់ គឺថា... យ៉ាងណាក៏មិនឲ្យជនច្រឡេងខាមនេះជាន់ឈ្លីនាងបានតាមអំពើចិត្ត ដូចដែលធ្លាប់ធ្វើទៅលើស្ត្រីផ្សេងៗនោះដែរ...។...

សិទ្ធិគុណ ក្រហមភ្នែកគ្លៃ ដោយភ្លើងកំហឹងដោយគិតថាទង្វើហិង្សារបស់ខ្លួនមិនអាចសម្លុតសូម្បីតែមនុស្សស្រីទន់ខ្សោយម្នាក់។សន្ទុះចិត្តចង់ឈ្នះនៅតែរោលរាលមិនងាយរលត់ឡើយ...គេស្រែកសន្ធាប់លាន់ខ្ទរផ្ទៃភោជនីយដ្ឋាន ៖

ចាប់នាងមកវិញ...!...

កងការពារ សិទ្ធិគុណ ស្ទុះប្រាវទៅរកឌីម៉ា ដែលឈានដើរទៅមុខស្ទើរមិនចង់រួច។នៅម្ខាងនោះ អ្នកស្រីកុលាបឈរក្រពាត់ដៃ គ្រវីក្បាលបង្ហាញទឹកមុខហួសចិត្ត ហាក់ចង់បន្ទោសថាតរុណីយើងរឹងទទឹងក៏គ្មានប្រយោជន៍អ្វីដែរ...។

តែអ្វីៗហាក់ប្រែប្រួលទន្ទឹមនឹងសំឡេងមួយលាន់ឡើងឯមាត់ទ្វារភោជនីយដ្ឋានបង្អាក់ចលនាកងការពារទាំងអស់របស់ សិទ្ធិគុណ ឲ្យផ្អាកសកម្មភាពមកវិញ។

មានរឿងអីក៏អ៊ូអរ ម្ល៉េះ ?...

អ្នកដែលភ្ញាក់ផ្អើលជាងគេក្នុងពេលនេះ មិនមែន សិទ្ធិគុណទេ... ប៉ុន្តែគឺឌីម៉ា។ស្រស់ស្រីងើបមុខយ៉ាងរហ័សសម្លឹងទៅរកម្ចាស់សូរស័ព្ទដែលមាណវី ប្រាកដក្នុងចិត្តថា នាងធ្លាប់ស្គាល់គេយ៉ាងច្បាស់ និងចងចាំអស់មួយជីវិតទៀតផង ។...

ក្រសៃភ្នែកមុតដូចរាជសីនៃបុរសដែលទើបនឹងបង្ហាញខ្លួនបានផ្តោតសម្លឹងមករកអ្នកគ្រូបង្ហាញម៉ូតរូបស្អាតមុនពេលដែលនាងសម្លឹងឆ្ពោះទៅរកគេទៅទៀត...។ផ្ទៃមុខភ្លឺ ថ្លានៃបុរសសម្បុរស្រអែមដែលបង្កប់ជាមួយនូវអំណាចអាថ៌កំបាំង ស្វាគមន៍មករកឌីម៉ានូវផ្កាញញឹមមួយយ៉ាងស្រស់តែក៏មានអត្ថន័យល្មមឲ្យមាណវីព្រឺខ្នងដូចជួបព្រាយបិសាចអញ្ចឹងដែរ ។...

អ្នកគ្រូវ័យក្មេងឈ្ងោកមុខមកវិញ លែងហ៊ានមើលទៅគេល្មមពេលលាន់លឺស្នូរជើងមនុស្សចូលមកព្រូៗច្រើនជាងមុន។សំឡេង សិទ្ធិគុណ លាន់លឺឡើងជ្រែកកាត់ចង្វាក់បេះដូងស្រស់ស្រីឌីម៉ាដែលកំពុងលោតខុសចង្វាក់ ៖

បងរាម អញ្ជើញមកមើលបុប្ផាអាស៊ី នៅកោះបាលីនេះ ម៉េចក៏ចាំបាច់នាំមនុស្សមកច្រើនម្ល៉ឹងៗ ?នេះកន្លែងគេគយគន់ទេសភាព...មិនមែនទីលានប្រណាំងសេះនៅហុងកុងទេ !...

រាមនរិន្ទគឺជាឈ្មោះនៃបុរសដែលទើបនឹងបង្ហាញខ្លួន។

មនុស្សម្នាក្នុងសង្គមជាន់ខ្ពស់រមែងតែងស្គាល់ថាគេជាអភិជនវ័យក្មេងដែលមានឈ្មោះល្បីនិងមានសកម្មភាពលេចធ្លោផ្តាច់សម័យកាល។

ដោយមានឪពុកជាអ្នកតំណាងរាស្ត្រនិងម្តាយកាលពីនៅរស់ជាស្ត្រីដ៏មានអំណាចក្នុងក្រុមប្រឹក្សាវិនិយោគជាតិ រូបគេផ្ទាល់កំពុងត្រូវបានមតិសាធារណៈយល់ថា ជាធនធានយុវជនដ៏មានអនាគតក្នុងឆាកនយោបាយខ្មែរ។

ជាមួយនឹងប្រយោគស៊កសៀតរបស់ សិទ្ធិគុណ ក្នុងន័យមិនពេញចិត្តនូវវត្តមាន រាមនរិន្ទ និងកងការពារច្រើនសន្ធឹកនោះ... រាមនរិន្ទនៅតែញញឹមស្រស់ដើរមួយៗចូលមក។...សំឡេងគេបន្លឺឡើងនូវប្រយោគទី២ ល្មមពេលដែលរាងកាយគេឈានចូលមកកៀកនឹងឪម៉ាល្មម ៖

បងមកបាលី ក្រៅពីមកមើលបុប្ផាអាស៊ី...នៅមានកម្មវិធីពិសេសមួយទៀត... គឺមកញ៉ាំបាយល្ងាចជាមួយមិត្តចាស់ ឃើញប្អូនគុណខឹងឡូឡាបោកចានបោកកែវបងខ្លាចតែធ្វើឲ្យមិត្តភ័ក្តិបងភ័យទេ... បានជាឆៀងចូលមកមើល។ទប់ចិត្តខ្លះទៅណ៎ាប្អូន... យើងមកនេះគឺមកសប្បាយទាំងអស់គ្នា... ។

បាតដៃក្តៅអ៊ុនៗ តែទន់ល្វក់មួយ បានលូកមកក្រសោបម្រាមទាំងប្រាំរបស់ មាណវីឪម៉ាដែលកំពុងត្រជាក់ដូចមនុស្សស្លាប់។...នាងភ្ញាក់ក្រញាងងើបមុខសម្លឹងម្ចាស់បាតដៃព្រហើននោះទាំងស្មារតីមិននឹងន...ទឹកមុខ រាមនរិន្ទ នៅតែរក្សាស្នាមញញឹម ទោះបីគេដកភ្នែកពី សិទ្ធិគុណ មកសម្លឹងនារីនៅកៀកបង្កើយហើយក្តី... ក៏បបូរមាត់គេនៅតែវាចាបន្ត ៖

បងថា បើ គុណ ចង់អញ្ជើញអ្នកគ្រូឪម៉ាទៅពិសាបាយល្ងាចជាមួយ ក្រែងតែខកបំណងហើយទេដឹង ព្រោះអ្នកគ្រូដូចជាមានណាត់ជាមួយបងស្រេចទៅហើយ.!..រឺមួយក៏ បាយរួមគ្នាម្តងទៅក៏ល្អមិនថាអញ្ចឹង?

ក្រសែភ្នែករាមនរិន្ទ ដែលសម្លឹងមករកឪម៉ាហាក់រង់ចាំចម្លើយស្រេបបានធ្វើឲ្យម្រាមដៃទាំងប្រាំដែលបម្រុងនឹងដកចេញពីប្រអប់ដៃគេនោះ លែងហ៊ានកម្រើក។ឪម៉ាត្រូវបង្ខំចិត្តបន្លឺតិចៗស្ទើរមិនចង់លឺ ៖

រីករាយណាស់ដែលបានជួបលោកប្រុសរាមនៅទីនេះ !...

នាងនៅពេលភ្នែកប៉ះគ្នានាងឃើញបុរសមកពីត្រកូលអ្នកនយោបាយញញឹមមករកខ្លួនវិញធ្វើព្រងើយហាក់មិនអើពើដល់ភ្លើងកំហឹងនឹងការខកចិត្តដែលកំពុងអណ្តែតលើផ្ទៃមុខសិទ្ធិគុណនោះសោះ។

បើទោះបីពាណិជ្ជករឈោមរាវសិទ្ធិគុណជាយុវជនពោរពេញដោយគំនិតរឹងរូសយ៉ាងណាក៏ដោយ... ក៏ចំពោះមុខវត្តមានរាមនរិន្ទ គេត្រូវបង្ខំចិត្តសង្កត់ភ្លើងកំហឹង... ដោយប្រែទឹកមុខទៅជាសើចខឹកៗ៖

អូ...ហូ !... តាមពិតមិត្តចាស់បងរាម គឺអ្នកគ្រូបង្ហាញម៉ូតសោះ ... អូខេទេតើ!. តាមសប្បាយ ...!. ខ្ញុំមិនហ៊ាននៅរំខានទេ... ចាំជួបគ្នាលើកក្រោយទៀតណាបង !...

គេងាកទៅឲ្យសញ្ញាកូនចៅ រួចចាកចេញទៅដោយទាំងមិនភ្លេចដៀងភ្នែកមកមើលស្រស់ស្រីឌីម៉ាជាលើកចុងក្រោយផង... ។...

សន្សឹមៗនាងក្រមុំដកដៃចេញពី ប្រអប់ដៃរាមនរិន្ទ...ពេលនោះដៃរនាងលឺសំឡេងគេលាន់មកស្រាលក្បែរត្រចៀក ៖

បែកគ្នាយូរបន្តិចហើយមែនទេ ?

ឌីម៉ាមានអារម្មណ៍ធ្ងន់កណ្តុកដោយភាពច្រាសច្រាល...ក្នុងនោះមានចម្រុះគ្នាទាំងភាពភិតភ័យ ខ្វល់ខ្វាយ ចុះចាញ់ និងអៀនខ្មាស... ។

តើនារីណាម្នាក់ដែលមានសេចក្តីក្លាហាន និង ប្រឈមមុខធ្វើដូចមិនដឹងរឿងចំពោះមុខមនុស្សប្រុសដែលធ្លាប់ដណ្តើមបាននូវរាត្រីរបស់ខ្លួននោះ ។

ឌីម៉ានឹកឃើញមួយរំពេចដល់ពេលមួយ ដែលមនុស្សម្នាក់បានប្រើប្រាស់ នូវអំណាចទឹកប្រាក់របស់គេមកទិញយកកិត្តិយសជាស្រីក្រមុំរបស់នាងទៅព្រោះនាងត្រូវការប្រាក់ដើម្បីរំដោះប្អូនពីការស្លាប់។មនុស្សម្នាក់នោះ បានបន្សល់នូវស្រមោលនៃក្តីអាម៉ាស់... ឈឺចាប់... និងអពមង្គលដល់នាង ដោយសារតែគេមានប្រាក់...ហើយគេគឺ រាមនរិន្ទ ដែលកំពុងនៅក្បែរនាងទាំងសាច់ ទាំងឈាមនោះឯង ។

ភ្នែកដែលធ្លាប់យំ... វាអាចខំអត់ទ្រាំមិនសម្រក់ទឹកភ្នែក... ដើម្បីកុំឲ្យអ្នកដទៃមើលមកថាម្ចាស់វាទន់ខ្សោយពេក... តែក្នុងចិត្តវិញ... កំពុងតែទ្រហោយំយ៉ាងសោកសៅទៅហើយ... ។នាងលើកដៃទាំងពីរផ្គុំ ទៅរកគេទាំងពោលដោយមិនហ៊ានសម្លឹងមុខ ៖

ជម្រាបលាសិនហើយ !...

ស្រស់ស្រីបែរខ្លួនចាកចេញទៅ... ទាំងបន្ទោសវាសនាខ្លួនថា ហេតុអ្វីបែរជាមកជួបមុខគេវិញទាល់តែបាន?ហើយនាងថែមទាំងស្មានដឹងទៀតផងថា... រាមនរិន្ទ សិទ្ធិគុណ គឺជាក្រុមមនុស្សតែមួយ ដែលមើលមកមនុស្សស្រីជាចំណី សម្រាប់ជាន់ឈ្លី ប្រមាថ មើលងាយតែប៉ុណ្ណោះ។

កងការពារដែលឈរក្បែរឌីម៉ាជាងគេបន្លឺកាត់ទាំងលើកដៃរាំងពីមុខជាប់ ៖

អ្នកគ្រូឌីម៉ាកុំទាន់ទៅ!...

ធីតាយើងជ្រួញចិញ្ចើម។សេចក្ដីមួហ្មងលេចឡើងក្នុងចិត្តសារជាថ្មី... នាងងាកមករក រាមនរិន្ទ ដែលនៅពីក្រោយខ្នងនៅឡើយ...មានសំណួរច្រើនណាស់ដែលតរុណីចង់សួរទៅកាន់គេឲ្យស្មើទៅនឹងចិត្តខឹងដែលគេបង្ហាញខ្លួនមកឲ្យនាងសៅហ្មង...តែក្រឡេកទៅឃើញមុខគេកាលណា...នាងរកវាចាទៅកាន់គេមិនរួចសូម្បីតែមួយម៉ាត់ ។...

រាមនរិន្ទ ញញឹមឈរជ្រែងហោប៉ៅ សម្លឹងមកផ្ទៃមុខដែលស្រស់ស្អាតដូចគំនូរ នៃអ្នកគ្រូវ័យក្មេង... គេបន្លឺមកកាន់នាងសារជាថ្មី ៖

ក្រែងថាទៅបាយជាមួយគ្នាអ្ហ៎?

ឌីម៉ាតបដោយមិនរារែក ៖

ខ្ញុំមិនធ្លាប់បានសន្យារឿងហ្នឹងទេ !...

នរិន្ទហាក់ ដឹងចរិតនាងច្បាស់បន្ទាប់ពីថ្នាក់ដឹកនាំនៃក្រុមកិន្នរីហ្វេសិនរូបនេះថ្លើមធំពាសសមុទ្រដល់ថ្នាក់បំបាក់មុខសិទ្ធិគុណអោយគេខឹងក្រោធបោកកម្ទេចរបស់របរពេញភោជនីយដ្ឋានបន្សល់កាកសំណល់ពោរពាសនៅឡើយ។គេទៅជាអស់សំណើចចំពោះមនុស្សស្រីខ្លួនតូចតែឬក៏ធំដុំម្នាក់នេះ។នាយសើចចុងមាត់ហើយដើរត្រឹកៗមកប្រឈមចំពោះមុខនាង ៖

ចាំបាច់ច្បាស់លាស់អីពេកបើមនុស្សស្គាល់គ្នាយូរៗជួបគ្នាម្ដងនេះ?

ឌីម៉ាព្រិចភ្នែក... ភាពស្រងូតកំពុងលេចចេញយ៉ាងច្បាស់លើវង់ភក្ត្រដែលឈ្ងោកជាប់។

សូមទោស !... សិស្សរបស់ខ្ញុំកំពុងរង់ចាំ!ធម្មតា គឺខ្ញុំញ៉ាំបាយជាមួយពួកគេ...!...

ទឹកមុខ រាមនរិន្ទ ប្រែទាំងជាស្មើ។បើនាងនិយាយសូម្បីតែមុខ ក៏មិនមើលគេផង តើចាំបាច់អីត្រូវគួរសមនឹងនាងយូរដល់ម្លឹង?

បាន!មានអី!បើចង់ទៅណាស់!ដោះស្រាយរឿងចាស់អោយចប់សិនទៅអញ្ចឹង!

គេដើរពីមុខនាងចាកចេញទៅ... បន្សល់នូវភាពស្មុគស្មាញគ្របដណ្តប់ក្នុងចិត្តស្រស់ស្រីឌីម៉ា។ កងការពារដដែលនិយាយមកកាន់ ធីតារងគ្រោះចុះទឹក ក្រពើឡើងលើខ្លា ៖

អញ្ជើញ !...

ឌីម៉ាសារជាថ្មីនៅតែងាករកជំនួយពីអ្នកស្រីកុលាបព្រោះនាងមានតែគាត់ជាចាស់ទុំនៅទីនេះ ។តែម្តងនេះនាងប្រែទៅជាងឿងឆ្ងល់ព្រោះស្ត្រីរូបនេះធ្វើមុខស្លាំងអែ...សសៀរខ្លួនបម្រុងចាកចេញពីភោជនីយដ្ឋាន តែត្រូវកងការពារ២នាក់តាមកៀងជាប់ហើយបង្ខំអោយឲ្យទៅតាមពីក្រោយ រាមនរិន្ទ ។ចំណែកទឹកមុខត្រជាក់ស្រេបនៃកងការពារម្នាក់ដែលនៅក្បែរខ្លួននាង... ទោះបីគេនៅបន្តប្រើពាក្យ គួរសមប៉ុន្តែក៏ល្មមអាចទស្សន៍ទាយដឹងមុនបានដែរថា បើនាងមិនធ្វើតាមទេ..នាងនឹងត្រូវគេចាប់បង្ខំមិនខាន... ។

ឌីម៉ាដើរមួយៗទៅតាម ដែលកងការពារបង្ហាញ...អារម្មណ៍ដែលមួហ្មងត្រូវជំនួសដោយក្តីពីភាល់សង្ស័យថាខ្លួនអាចនឹងជួបរឿងមិនល្អច្បាស់ណាស់...ព្រោះនាងបានឃើញពួកកងការពាររបស់ រាមនរិន្ទ រុញបង្ខំអ្នកស្រីកុលាប ដោយកាយវិការគ្មានការគួរសមទាល់តែសោះ ។...

អ្នកគ្រូនិងស្ត្រីមេអណ្តើកត្រូវបានគេនាំមកជាន់ទី៩ នៃសណ្ឋាគារដែលប្រកបដោយភាពស្ងាត់ជ្រងំ... ខុសប្លែកពីភោជនីយដ្ឋានឯជាន់ខាងក្រោម ។...

នៅក្នុងបន្ទប់ធំទូលាយដែល រាមនរិន្ទ កំពុងឈរបែរខ្នងក្រេបទឹកក្អឹកៗសម្លឹងទៅរានហាលខាងក្រៅ ស្ត្រីឈ្មោះកុលាបត្រូវបានរុញទៅអោយអង្គុយលើសាឡុងដោយប្រដាប់ ប្រភីង។... ឌីម៉ានៅឈរទ្រឹងដូចគ្មានព្រលឹងក្នុងខ្លួនកណ្តាលផ្ទៃបន្ទប់ដែលត្រជាក់ស្រឹប...។

គន្ធទឹកក្រអូបដែលម្ចាស់ប្រុសគ្រប់គ្រងទឹកន្លែងតែងនិយមប្រើប្រាស់អណ្តែតមកប៉ះនាសាធីតាកាលណា បានដាស់ឲ្យនារីនឹកឃើញដល់អនុស្សាវរីយ៍ជូរចត់ដែលខ្លួនធ្លាប់ប្រទ្បាក់

ប្រទ្បូសជាមួយនាយហើយដែលនាងជឿជាក់ថាមួយជីវិតនេះ...នាងនឹងត្រូវស្រមោលអតីតកាលនោះតាមលងបន្លាចឲ្យអាម៉ាស់ជានិច្ចហើយ ។

ចាប់តាំងពីរាត្រីមួយនោះ រាត្រីដែលនាងបានជួប គេជាលើកដំបូងនិងចុងក្រោយបង្អស់ បុរសនេះក៏ប្រហែលមិនបានចាំមុខនាង និងមិនបានទាំងនឹកឃើញដល់រឿងរ៉ាវដ៏មានតម្លៃបំផុតក្នុងជីវិតរបស់ស្ត្រីវ័យក្រមុំដ៏អភព្វម្នាក់នេះផង ចុះម៉េចក៏ពេលនេះព្រហ្មលិខិតធ្វើអោយនាងត្រូវវិលមកជួបមុខគេវិញធ្វើអ្វី?តើមានរឿងអ្វីដែលនាងចាំបាច់ត្រូវប្រឈមរវីមរវាមនឹងគេទៀត?

ផាំង...ខ្ទាយ

ជាលើក ទីពីរដែលអំបែងកែវត្រូវបោកកម្ទេចទៅនឹងជញ្ជាំងបន្ទប់រុះរោយកូនអំបែងចាំងឆ្វាចដូចគាប់ពេជ្រថ្មៃមកក្បែរជើងនារីរូប ល្អ។ សម្រែកដ៏រន្ធត់របស់ស្ត្រីមេអណ្តើកលាន់ឡើងដាស់សតិឌីម៉ា ដែលកំពុងបែកខ្ញែកនោះ... ឲ្យវិលមករករាងកាយវិញ...។

នាងស្រឡាំងកាំង។ រាមនរិន្ទ លះបង់ស្នាមញញឹមនៅឯបន្ទប់ខាងក្រោមជំនួសមកវិញនូវ ទឹកមុខស្មើ ធេងស ស្លេកដោយកំហឹង។

"ការបោកកែវចោលជាទម្លាប់របស់ពួកអ្នកមានមែនទេ?(នាងដណ្តឹងសួរក្នុងចិត្ត)"

ទោះបីអ្នកស្រីកុលាបមិនបានទទួលការវាយដំច្រំ ធាក់ប៉ុន្តែឌីម៉ាដឹង ថាគាត់ស្រែកដោយរន្ធត់គ្មានអ្វីប្លែកទេព្រោះបើសូម្បីតែ នាងក៏កំពុងភ័យភិតភ័យស្ទើរគាំងបេះដូងទៅ ហើយដែរ។

ក្នុងមួយខណៈដែលស្រស់ស្រី ឌីម៉ាកំពុង ភាន់ភាំងនាងលឺសំឡេងរាមនរិន្ទពោលមកត្រជាក់ស្រែង៖

ខ្ញុំអោយឱកាសមួយអោយមីងបកស្រាយ!

អ្នកស្រីកុលាប ដែលញ័រចំប្រប់ដូចសត្វកណ្តុរលង់ទឹកក្នុងសាស្ត្រាសំណើចខ្មៅរប្រវេប្រវា ចូលទៅរក រាមនរិន្ទ ក្រោមរង្វង់ភ្នែកមូលក្លុំ ដោយក្តីងឿងឆ្ងល់របស់អ្នកគ្រូរូប ស្អាត ៖

លោកប្រុស រាម សូមទោស !... មីងខុសហើយ !...

នៅពេលរាមនរិន្ទមិនចេញស្តីមួយមាត់...កងការពារពីរនាក់លូកដៃមកទាញអ្នកស្រីកុលាបឡើង ហើយទះពីរបីដៃផ្ទួនៗធ្វើអោយភ្លាត់មាត់បញ្ចេញសម្រែក ឈឺចាប់លាន់ខ្ទរផ្ទៃបន្ទប់...។

ឌីម៉ាឃើញកងការពារម្នាក់ផ្សេងទៀតក្តាប់ដៃតម្រង់រាងកាយអ្នកស្រី កុលាប ដែលកំពុងទន់ភ្លៀកនោះទៀត... នាងភ្លាត់មាត់ស្រែកដោយមិនដឹងខ្លួន ៖

អត់ទេ!...

កងការពារនោះបង្អាក់ចលនាបន្តិច... ដោយងាកមករកឌីម៉ា រួចទើបដៀងភ្នែកមើលទៅរករាមនរិន្ទ..។ឌីម៉ាក៏ងាកភ្លែតទៅរករាមនរិន្ទដែរ... នាងឃើញគេដើរមួយៗមកអង្គុយគងអន្ទាក់ខ្លាលើសាឡុងធ្វើព្រងើយ។ម្តងណេះនារីបង្ហាញម៉ូតយាត់លែងទាន់ហើយ...កងការពារដៃឆ្វេងនោះ ពន្លែងដៃទី៣ធ្វើឲ្យអ្នកស្រីវ័យចំណាស់ដួលវិលទៅប៉ះនឹងជញ្ជាំងបន្ទប់ស្រែកលែងចេញ... ។

ឌីម៉ាស្ទុះចូលទៅឈរក្បែររាមនរិន្ទ។ គេក៏ងើបមុខមើលតបមកនាង។ទឹកមុខដែលគ្មានស្នាមញញឹមតែហាក់រសាយពី កំហឹងវិញបានឆ្លើយតបមកកាន់នាងនូវពន្លឺខ្សែភ្នែកដែលមានន័យថា នាងចង់យ៉ាងម៉េច?

សេចក្តីភ័យ ព្រួយនិងងឿងឆ្ងល់លើ ផ្ទៃមុខតរុណីមិនបានធ្វើអាយបុរសមកពីគ្រួសារមានអំណាចអាណិតអាសូរឡើយ ។គេនៅតែសម្លឹងមុខនាងហើយញាក់ចិញ្ចើមក្នុងន័យផ្តើន។

នាងដឹងហើយថា គេមិនសប្បាយចិត្តដែលនាងមិនបានទុកមុខអោយគេនៅខាងក្រោម។នាងចង់និយាយតែនិយាយអ្វីក៏មិនចេញបានត្រឹមបើកភ្នែកមូលក្លុំដែលប្រែទៅជាសើមបន្តិចម្តងៗ។

យំធ្វើអី?

សំឡេងគេសួរមកហាក់ឌឺដង។នាងតបវិញបានតែប្ញនម៉ាត់គត់៖

វាយគាត់ធ្វើអី?

ភាគទី៣

នរិន្ទ ដកភ្នែកចេញពី វង្សភក្ត្រស្លាំងរបស់នារីតូចច្រមក់ ដោយដៀងមកសម្លឹងដៃនាងដែលញ័រទទ្រើកក្តាប់លើសំពត់ផ្កាគ្របលំអលើជើងមួយគូរស្រស់ប្រផូរ។គេញញឹម តែមិនមែនស្នាមញញឹមដែលគួរអោយកក់ក្តៅប៉ុន្មានឡើយ ៖

ប្រាកដថាខ្លួនឯងអត់មានរឿងអីទេ?... បានជាហ៊ានសួរនាំជួសអ្នកដទៃ ?...

ពន្លឺភ្នែកមុតថ្លាដែលរាមនរិន្ទ ជនត្រកូលខ្ពស់ដែលងើបមុខមកសម្លឹងផ្ចើននាងសារជាថ្មីធ្វើឲ្យក្ដីសង្ស័យមួយផុសឡើងក្នុងចិត្តឌីម៉ា ថានាងក៏មិនទាន់ប្រាកដថាបានរួចខ្លួនដែរ...តែនាងមិនដឹងទេថា... ពួកគេចង់ធ្វើអ្វីខ្លួន... ហើយដោយសារមូលហេតុអ្វីនោះ ...។...

នាងថយក្រោយក្រាកមួយជំហានដោយលុះក្រោមការបំភ័យ... តែទន្ទឹមនឹងនោះនាងតាំងចិត្តតបទៅកាន់ រាមនរិន្ទ ទាំងសម្លឹងមុខគេត្លែ ៖

តែពួកលោកគ្មានសិទ្ធិទេ...លោកក៏ចេះច្បាប់ដែរមែនទេ?លោកបានរៀនច្បាប់ជ្រៅជ្រះជាងអ្នកផង ផងមែនទេ?

ស្នាមញញឹមលេចចិញ្ចាចលើផ្ទៃមុខរាមនរិន្ទ... គេរអ៊ូតិចៗទាំងសម្លឹងនាងដោយក្រសែភ្នែកអណ្ដែតអណ្ដូង ៖

បានសម្ដីណាស់ទេតើ !...

ពន្លឺភ្នែកដែលបង្កប់ នូវអំណាចអ្វីម្យ៉ាងដោយអាថ៌កំបាំង បានបង្ខំឲ្យ ឌីម៉ាចាំបាច់ ត្រូវឈានជើងថយក្រោយក្រាកៗដោយមិនដឹងខ្លួន...។

"គេគិតធ្វើ អីយើង?រឺមួយ គេដឹងការពិតអស់ហើយ?មិនអាចទេ!!"

ល្មមពេលដែលសំនួរជាច្រើនផុសឡើងមក ឌីម៉ាទៅជាវិលវល់លែងអាចគ្រប់គ្រងស្ថានការណ៍បាន។នាងនៅសម្លឹងគេត្លែទាំងទឹកមុខភិតភ័យ។ពេលធម្មតានាងគ្មានទាំងភាពក្លាហានក្នុងការប្រឈមនឹងបុរសម្នាក់នេះផងកុំ ថាឡើយក្នុងស្ថានភាពអាក្រក់បែបនេះ។

ទន្ទឹមនោះដៃរអ្នកស្រីកុលាបប្រវេប្រវាមកក្បែរ រាមនរិន្ទ ទាំងពោលអង្វរដោយយំសស្រាក់៖

លោកប្រុសរាម ! មីងខុសហើយ....មីងរាងចាលហើយ... !... មីងចាស់ហើយកុំធ្វើបាបមីង!

រាមភីនន្ទដកភ្នែកចេញពីឌីម៉ាយឺតៗ...គេងាកមករកអ្នកស្រីកុលាបដែលទន់ខ្លួននៅលើឥដ្ឋក្នុងកាយវិការអង្វរករ៖

សិទ្ធិគុណ ឲ្យលុយមីងឯងប៉ុន្មាន ?

ស្ត្រីនោះយំអណ្តឺតអណ្តក...តែមិនព្រមឆ្លើយ។គាត់ហាក់ដូចជាឆ្លើយមិនចេញក្នុងសភាពរបៀបអ្នកមានទោសកំហុសមែនប្រការ នេះនាំអោយឌីម៉ាកាន់តែខ្វល់ចិត្ត។នៅពេលដែលកងការពារស្ទុះចូលទៅលើកគាត់ឡើងនាងចាប់ភ័យតក្កមាសារជាថ្មីប៉ុន្តែ នាងស្រាយអារម្មណ៍មកវិញនៅពេលឃើញរាមនរិន្ទលើកដៃរាជាសញ្ញាថាកុំអោយបន្តសកម្មភាពហិង្សានោះទៀត។សំដីច្បាស់ៗលាន់ចេញមកពីមាត់គេ៖

ឈប់ធ្វើអញ្ចឹងទៅ!សម្រាប់គាត់ បញ្ជូនទៅអោយប៉ូលិសស្រុកខ្មែរ អោយគេដោះស្រាយពីរឿងជួញដូរមនុស្ស វា ល្មមអោយគាត់ដេកគុកដប់ ម្ភៃឆ្នាំទៅហើយ!

កងការពារទម្លាក់ស្ត្រីល្មោភប្រាក់ចោលទៅលើឥដ្ឋ។នាងលឺអ្នកស្រីកុលាប ដែលមុខត្រូវហើមពោរពេញដោយកណ្តាប់ដៃកងការពារនោះ ពោលទាំងខ្សឹកខ្សួល ៖

លោកប្រុសរាម !... លើកទោសឲ្យមីងម្តងទៅ... មីងខុសហើយ !...ថ្ងៃក្រោយមីងមិនហ៊ានរញ៉េរញ៉ៃជាមួយអ្នកគ្រូឌីម៉ាទៀតទេ!

ឌីម៉ាយល់ហើយ គេកំពុងខឹងដែលកាលពីមុននេះស្ត្រីនោះបានបញ្ចុកបន្សីខ្លួនអោយបុរសពាណិជ្ជករវ័យក្មេងនៅឯភោជនីយដ្ឋានជាន់ក្រោម។នាងរវើរវាយនឹកស្ងាត់ៗក្នុងចិត្តម្នាក់ឯង៖

រាមនរិន្ទ!ពាក្យជួញដូរមនុស្សក៏លោកចេះនិយាយដែរ!ប៉ុន្តែគួរសម្លឹងខ្លួនលោកវិញ! ទិញស្រីអស់ប៉ុន្មាននាក់ហើយ!មនុស្សស្មោកគ្រោក យកដៃចង្អុលគេពូកែណាស់!

រាមនរិន្ទ គងអន្ទាក់ខ្លាងាកមុខចេញ៖

ទុកពាក្យមីងទៅអង្វរតុលាការទៅ!

ឌីម៉ាដែលមិនធ្លាប់មានអារម្មណ៍ល្អជាមួយក្រុមបុរសអ្នកមានប្រាក់មានអំណាចសោះនោះកាន់តែយល់ថាវាខុសទំនងណាស់ បើទោះស្ត្រីនេះធ្វើអ្វីចំពោះនាងក៏គ្មានទាក់ទាមអ្វីនឹងរាមនរិន្ទសម្រាប់អោយគេមកចំណាយពេលខឹងដល់ថ្នាក់នេះដែរ។

នាងហារមាត់និយាយកាត់៖

លោកប្រុសរាម!ហេតុអ្វីលោកចាំបាច់ខឹងគាត់ដល់ថ្នាក់ហ្នឹង?ខ្ញុំចង់និយាយថា....

រាមនរិន្ទងាកមកសម្លឹងនាងភ្លាមព្រោះថាភាពភ្ញាក់ផ្អើលនឹងរឿងឆ្ងល់របស់នាងបែរជាអោយនរៈយល់ផ្សេង។គេគិតដោយហ្មងសៅ "រឺមួយនាងពេញចិត្តអោយ ខ្លួនត្រូវគេយកទៅលក់ដូរដូចសត្វធាតុកេតឪម៉ា"?អ្នកប្រុសដណ្តឹងសួរខ្លួនឯងស្ងាត់ៗ។

នៅចំពោះមុខវង់ភក្ត្រស្រស់ដូចសេកសោមដែលនៅក្បែរខ្លួនបង្អើយអ្នកប្រុសយល់ថាមិនអាចអត់ធ្មត់ចំពោះកំសួលចិត្តច្រណែនប្រចណ្ឌបានទេ គេនិយាយតបនាងផ្ទូង៖

អញ្ជឹងចង់លក់ខ្លួនណាស់ហ្អ?ចូលចិត្តសិទ្ធិគុណណាស់មែនទេ?កាលនៅខាងក្រោមចាំបាច់ធ្វើត្រឹមត្រូវធ្វើ អីអញ្ជឹង?

ពាក្យ"លក់ខ្លួន"បានធ្វើអោយនាងស្រងល់ ហើយពាក្យថា"ធ្វើឫកត្រឹមត្រូវ"បានសំពងអោយនារីតូចស្រស់ទ្រេតទ្រោតរិះដួល។

ចង់យំក៏យំមិនចេញ... ចង់បន្ទោសក៏ហារលែងរួច... នាងដឹងច្បាស់ថាអ្នកមាន ដូចរាមនរិន្ទនេះចិត្តកំណាចណាស់គ្មានធម៌មេត្តាទេ... សម្តីមើលងាយអញ្ជឹងក៏និយាយចេញមករួចដែរ។ តែធ្វើម៉េចបើនាង"ធ្លាប់លក់ខ្លួនមែន"តើអោយនាងហារតបវិញរបៀបណាទៅ?

នាងខាំមាត់ បង្កើនភាពរឹងមាំអោយរាងកាយដែលត្រូវបានធាក់ទម្លាក់ដោយពាក្យគ្រោតគ្រាតហើយដើរមួយៗទៅលើកគ្រាស្ត្រីរងគ្រោះឡើង។នាងនិយាយទាំងទឹកភ្នែក៖

តោះមីង!យើងត្រឡប់ទៅវិញ!

ស្ត្រីនោះបានឪម៉ាជួយលើកហើយគាត់នៅតែមិនព្រមឈប់ គាត់មិនត្រឹមតែមិនព្រមទៅជាមួយនាងទេ ថែមទាំងស្ទុះមកលន់តួម្ចាស់បន្ទប់នៅក្បែរជើងដ៏មាំទាំងគូរបស់គេ៖

លោកប្រុសរាម!មីងសុំទោស!លោកប្រុសជួយមីងជាលើកចុងក្រោយទៅ!មីងសុំទោស!កុំអោយប៉ូលិសប្តឹងមីង!

ឪម៉ាសម្លឹងទៅអ្នកស្រីកុលាប ដែលកំពុងបាក់ស្បាតចំពោះមុខទារុណកម្ម។នាងសួរគាត់បញ្ឈឺចិត្តបុរសអ្នកមាន៖

មីង!យើងលក់ខ្លួនក៏ដោយ..ទៅគេងជាមួយអ្នកណាក៏ដោយ!ទៅធ្វើ អីក៏ដោយ!មានទៅទាក់ទងអីជាមួយពួកគេ?មីងអង្វរគេធ្វើ អី?គេថ្លៃថ្នូរ យើងថោកទាប នៅមួយឡែកម្នាក់ទៅ! មីងកុំទៅអង្វរគេ!

បបូរមាត់រាមនរិន្ទរលេចផ្កាសំណើចប៉ុន្តែមានតែមីងកុលាបទេដែលដឹងថាឌីម៉ាកំពុងប្រឡែងលេងជាមួយនឹងភ្លើងកំហឹងដែលអាចធ្វើអោយនាងរលាក។គាត់ស្រាប់តែលើកដៃ ពីរសំពះបុរសដែលមានវ័យតិចជាង ធ្វើអោយឌីម៉ាកាន់តែមួហ្មង។នាងយល់ថាស្ត្រីនេះចប់ហើយ!គាត់ចុះចាញ់គ្រប់មនុស្សដែលគាត់យល់ថា គេមានលុយមានអំណាច គាត់ខ្លាចគេនោះខ្លាច ទាំងសូម្បីតែគេគ្មានសិទ្ធិអីមកថាស្តីគាត់ផង។នាងបន្តនិយាយដោយអណ្តឹតអណ្តក៖

មីង!មីងខ្លាចគេធ្វើ អី?បើមីងជាប់គុក ហើយបើខ្ញុំជាប់គុក មានអី!វាក៏ល្អមើលដែរទេតើ!ខ្លួនអ្នកថាគេហ្នឹង គេល្អប៉ុណ្ណាទៅ?បើមីងជាអ្នកជួញដូរមនុស្ស ខ្លួនគេ ខ្លួនគេក៏ជាអ្នកទិញដូរមនុស្សដូចគ្នា !

រាមនរិន្ទក្រោកដើរមួយៗមករកតរុណី។

នាងសម្លឹងទៅទីផ្សេងមិនខ្ចីសម្លឹងនាយតបឡើយហើយនាងប្រាប់ខ្លួនឯងស្ងាត់ៗ៖"

រាមនរិន្ទ!មនុស្សអាក្រក់!មនុស្សអាងអំណាច!ខ្ញុំគ្មានរឿងអីត្រូវខ្លាចអ្នកឯង!ហើយកុំសង្ឃឹមថាសម្លុតខ្ញុំបានទៀត!រឿងយើងចប់ហើយ!បើអ្នកឯងមានគុណលើខ្ញុំ អ្នកឯងក៏បានជាន់ ឈ្លីខ្លួនប្រាណខ្ញុំ រួចហើយដែរ!យើងគ្មានអីជំពាក់គ្នាទេ!"

ភ្នែកទាំងគូនៃបុរសអភិជនដៀងមករកស្រីស្រស់ដែលក្បែរខ្លួន... ។រាងកាយធំខ្ពស់របស់គេត្រូវបានតោងទាមដោយស្ត្រីមេអណ្តើកដែលស្រវាអោបជើងគេជាប់ដោយអំណាចនៃការភ័យព្រួយ។

លោកប្រុសរាមកុំធ្វើបាបប្អូន!គ្នា គ្នាមិនដឹងអីទេ!

ឌីម៉ាចងចិញ្ចើម។នាងឈ្ងោកសម្លឹងអ្នកស្រីកុលាបដោយហួសចិត្ត។ភាពជាមនុស្សម្នារបស់គាត់មានទៀតទេ? ដែលគាត់មកអោបជើងអង្វរគេរបៀបនេះ?នៅ ពេលនាងនិយាយលែងចេញ រាមនរិន្ទបម្រះជើងចេញពីស្ត្រីចំណាស់នឹងលើកដៃអោយសញ្ញាអោយអង្គរក្សទាញអូសគាត់ចេញទៅក្រៅ។ក្រុមកងការពារដកថយចេញពីបន្ទប់យ៉ាងរហ័ស ហាក់បីដូចជាយល់ចិត្ត

ថៅហ្វាយ... ដោយនាំទៅទាំងស្ត្រីចំណាស់ដែលបាក់ស្បាតហើយថែមទាំងទាញទ្វារបិទឲ្យទៀត... ។

ឪម៉ាងាកសម្លឹងជុំវិញខ្លួនដែលនៅសល់តែពីរ នាក់តទល់បើមិនរត់ទើបចំ ឡែក។ស្រី ស្រស់ប្រញាប់ប្រញាល់ចាកចេញចោលក្រសៃភ្នែកបុរសសម្បុរស្រអែមទៅតាមពីក្រោយអ្នកស្រី កុលាប... តែរំពេចនោះ រាមនរិន្ទស្រវាចាប់ដៃនាងជាប់... ។

អ្នកគ្រូបង្ហាញម៉ូតក៏គួរតែដឹងដែរថា... ពេលនេះចង់រួចខ្លួនពិតជាយ៉ាប់បន្តិចហើយ... ព្រោះគេមិនត្រឹមតែចាប់ដៃមាណវីយើងប៉ុណ្ណោះទេ... គេប្រើកម្លាំងទាញរាងកាយតូចតន់ទាំងមូលមកក្រសោបពេញទាំងរង្វង់ដៃតែម្តង ។

សំឡេងគេរអ៊ូតិចៗមកកាន់តរុណីដែលស្ថិតក្នុងរង្វង់ដៃ ៖

ចង់លក់ខ្លួនមែនទេ!មានអ្នកទិញទេតើ!អោយតែនិយាយគ្នាត្រង់ៗអញ្ចឹង!

ភ័យណាស់ តែក៏ក្តៅចិត្តណាស់ដែរ ឪម៉ាតបទាំងខាំមាត់៖

តែខ្ញុំមិនលក់ខ្លួនអោយលោកទេរាមនរិន្ទ!ចេញទៅ!

នារីរើ បម្រះធ្វើអោយអ្នក ផ្ទុយភេទកាន់តែចង់អោបរឹត។នាងកាន់តែហ្មងសៅនាយក៏កាន់តែមានៈ។

គេពោលសួរទាំងមួម៉ៅនឹងការប្រកែកប្រណាំងរបស់ស្រស់ស្រី៖

ធ្វើជ្រូកកុំរាទឹកក្តៅ!ហើយបើជ្រុលជាចង់ធ្វើជាទំនិញហើយ ចាំបាច់អីរើសមុខអ្នកទិញនោះ?

អស់មធ្យោបាយតតាំងដោយកម្លាំង តរុណីប្តូរមកលើកដៃទាំងពីរបាំងពីមុខ ដើម្បីកុំឲ្យរាងកាយប៉ះទៅនឹងដងខ្លួន រាមនរិន្ទទាំងស្រុងពេក ហើយខំងាកមុខចេញគេចពីច្រមុះបុរសអភិជនដែលចេះតែឈ្ងោកមករកនោះ...។

តាមពិតគេមានបំណងប្រដៅអ្នកស្រីកុលាបដើម្បីការពារនាង ហើយនាងក៏មិនមែនជាគោលដៅរបស់គេនៅកោះបាលីដែរ។ ក្នុងបេះដូងរាមនរិន្ទនៅតែគ្មានស្លាកស្នាមកេតឪម៉ាដូចកាលពីដំបូងមកអញ្ចឹង តែព្រឹត្តិការណ៍នៅជាន់ខាងក្រោម សកម្មភាពងប់ងុលនឹងសម្រស់នាងរបស់បុរសក្មេងសិទ្ធិគុណ ព្រមទាំងសម្តីគឃ្លើនបញ្ឈឺរបស់ឪម៉ាបានសម្រុកព្រមគ្នាក្នុង

អារម្មណ៍បុរសមកពីគ្រួសារអ្នកមានយសសក្តិអោយគេផ្ទុះឡើងនូវសន្ទុះចិត្តគគ្រឹតក្នាញ់ដោយឯក ឯង។គាប់ជួនទង បុប្ផាកំពុងបង្អួតលំអងគន្ធពិដោរយ៉ាងស៊ីវិល័យក្នុងដៃកន្លង់ទៅហើយ អោយរាមនរិន្ទទប់ចិត្តមិនបង្ក្រាបនាងខ្លះម៉េចនឹងកើត។គេរាវដៃទៅរកខ្សែចងអាវដែលនៅបង្អួតលើផែនទ្រូងក្រហមព្រឿងៗក្នុងពេលកែវភ្នែកទាំងគូរប្រែទៅជាក្រហមដោយអំណាចកាមា។

លោកប្រុសរាម!សូមទោស!(សព្ទញ័រៗដាច់ៗរបស់ឌីម៉ាទាញគតិរាមនរិន្ទត្រឡប់មកវិញ)

រាមនរិន្ទបង្អង់ដៃបញ្ឈប់ភាពកម្រោលទៅតាមអត្ថន័យអង្វរករផុសចេញពីទឹកមុខស្រងូតស្រងាត់នៃស្រីម្នាក់ដែលគេធ្លាប់ទទួលបានពីនាងនូវរាត្រីទី១ យ៉ាងផ្អែមល្ហែម...។គេគិតក្នុងចិត្តទាំងក្រអឺត៖

"អញ្ចឹងដដែល ចាំបាច់ធ្វើគ្រាន់បើម្លេះ?"

រាមនរិន្ទ ស្តាប់លឺតែស្នូរដើរខុសចង្វាក់នៃប្រអប់បេះដូងតរុណីរូបល្អដែលស្ថិតនៅក្នុងលង្វែកទ្រូង... រួមជាមួយនឹងប្រយោគអង្វររបស់ធីតាយើង ៖

កុំធ្វើអញ្ចឹង !...

បបូរមាត់ក្រហមឆោមញ័រទទ្រើកប្រាប់នាយជាស្រេចហើយថាអ្នកលក់ខ្លួនម្នាក់ នេះគ្មានជំនាញអាជីពនឹងមិនបានត្រៀមខ្លួនល្អទេ ។បើនាយនៅតែបង្ខំទៀត វាក្លាយទៅជាករណីរំលោភសេពសន្ថវៈច្បាស់ណាស់។គេលែងដៃពីនាងយឺតៗតែមិនចោលក្រសែភ្នែកលើផ្ទៃមុខដែលសស្លាំងដូចក្រដាសឡើយ។

បបូរមាត់បុរសអភិជននិយាយសារជាថ្មី៖

បើអញ្ចឹងទេ សម្តីកុំអោយថ្លោសពេកកេតឌីម៉ា!

ដូចរួចពីស្លាប់ នាងដកថយចេញពីគេមួយជំហានហើយទាញតម្រង់សំលៀកបំពាក់។អ្នកត្រូវយក្មេងបែរក្រោយចាកចេញទាំងមិន ដឹងទិសតំបន់។

**វគ្គទី២**

**អន្ទាក់ ស្នេហ៍លើកោះបាលី**

ឱម៉ារត់ចេញទាំងប្រផាប់ចាប់ប្រភីងវាក់ អើនឹងស្ត្រីឈ្មោះកុលាបនៅនឹងមុខបន្ទប់។នៅពេលប្រទះឃើញវត្តមានគាត់តែឯងនៅឆ្ងល្លាទីនោះ នាងស្ទុះអោបគាត់តែម្តង។ស្ត្រីមេអណ្តើកដឹងច្បាស់លាស់ថានាងកំពុងភ័យមិនទាន់បាត់ ទើបលើកដៃអង្អែលសក់នាងថ្នមៗដើម្បីបង្កើនអារម្មណ៍នឹងនមកវិញ។នារីស្វាងចេញពីភាពតក្កមាពេលណានាងងើបមុខងាកមើលជុំវិញខ្លួន។ដឹងថាអត់មានអង្គរក្សណា ម្នាក់របស់រាមនរិន្ទនៅទីនេះទៀតនាងនិយាយទៅរកស្ត្រីចំណាស់ភ្លាម៖

មីង!គេមានធ្វើអីមីងទៀតអត់?

ស្ត្រីនោះមិនឆ្លើយបែរជាអូសដៃនាងឆ្ពោះទៅកាន់ជណ្តើរយន្តរួចចុចប្រើ។ជំនិះនោះនាំអ្នកទាំងពីរមកដល់ជាន់មួយផ្សេងក្នុងពេលដែលឱម៉ាលាន់មាត់សួរ៖

យើងទៅណាមីង?

ស្ត្រីនោះលើកដៃអោយសញ្ញានារីបង្ហាញ ម៉ូតកុំអោយនិយាយលឺពេកទើបគាត់ពោលតប៖

ទៅបន្ទប់មីងសិនមីងមានការចង់ប្រាប់!

ឱម៉ាត្រូវស្ត្រីនោះទាញទៅទាំងនាងនៅងឿងឆ្ងល់និងមិនទាន់រសាយបាត់ពីអារម្មណ៍អាក្រក់។មកដល់ក្នុងកូនបន្ទប់តូចដែលជាទីស្នាក់បណ្តោះអាសន្នរបស់ស្ត្រីមេអណ្តើកលំដាប់អភិជននាងដាក់បង្គុយយឺតៗទៅលើគ្រែពូករបស់គាត់ដោយបង្ហាញសេរីភាពដែលបានធូរស្រាលចេញពីបរិយាកាសគួរអោយបារម្ភ។នាងផ្តេកខ្លួនសន្លឹមទៅលើកម្រាលពូកហើយបិទ ភ្នែកទាំងគូដែលនៅក្រហមដោយអំណាចជលនេត្រ។

ស៊យណាស់! មកគេងអូតែលក្បែរលោកប្រុសរាម!អ្នកណាទៅដឹងថា គេម៉ោទីនេះដែរទៅ?

នារីនៅបិទ ភ្នែកប្រមូលភាពរឹងប៉ឹងត្រឡប់មករាងកាយវិញក្នុងខណៈដែលក្លិនប្រេងខ្យល់ជះឆ្ងួលមក។នាងបើកភ្នែកសន្សឹមៗងាកមើលទៅស្ត្រីចំណាស់ដែលពោរពេញទៅដោយទឹកមុខឈឺចាប់ ហើយខិតខំព្យាបាលខ្លួនឯងនៅនឹងមុខតុសំអាង។

នាងយោងខ្លួនក្រោកដើរសន្សឹមៗទៅក្បែរគាត់ រួចលូកដៃទទួលយកដបប្រេងពីគាត់មកលាបអោយថ្នមៗលើមុខរបួសក្បែរមាត់និងភ្នែកដែលប្រែទៅជាហើមពោរ។

មីង អត់អីទេអ្ហេ៎?

ស្ត្រីនោះគ្រវីក្បាលតិចៗទាំងទឹកមុខឈឺចាប់។នារីបង្ហាញម៉ូតនិយាយបណ្តើរដៃជួយលាបព្យាបាលបណ្តើរ៖

ដឹងហើយថាពួកគេហ្នឹងសាហាវម្លឹងៗ មីងទៅរវីមរវាមអីជាមួយគេ?

ស្ត្រីនោះមិនឆ្លើយ ។ឪម៉ានិយាយបន្ថែម៖

មីងចាស់ហើយណ៎ា!នៅសុខៗមិនចង់ មករកស្លាប់ដល់ទីនេះទៀត?

ស្ត្រីនោះនៅតែរក្សាភាពស្ងៀមស្ងាត់។ឪម៉ាលាបប្រេងរួចរាល់នាង ក្រោកទៅចាក់ទឹកត្រជាក់មកអោយគាត់ក្រេបរួចថយទៅអង្គុយលើគ្រែវិញ។ដៃលូកក្នុងកាបូបបម្រុងចុចទូរស័ព្ទតែ ត្រូវសំនួរស្ត្រីចំណាស់លាន់មកកាត់៖

លោកប្រុសរាមអត់ធ្វើ អីឯងទេឪម៉ា?

នារីមិនឆ្លើយនាងឈ្ងោកមុខចុចទូរស័ព្ទរួចលើកមកនិយាយដើម្បីពង្វាង៖

អេនី!នាំគ្នាយើងញ៉ាំបាយមុនទៅណ៎ា!បន្តិចទៀតបានខ្ញុំទៅដល់!យប់នេះអ្ហេ៎?ក្នុងបន្ទប់ខ្ញុំអ្ហ៎បាន!ចាំខ្ញុំCalledជួបគ្នា!

មីងកុលាបប្រញាប់សួរភ្លាមសឹងថានារីដាក់ទូរស័ព្ទចុះមិនទាន់៖

អ្នកណាណាត់ឯងកូន?ហើយ ហើយប្រុងទៅណា?

ឪម៉ាដាក់ទូរសព្ទចុះហើយឆ្លើយដោយទឹកមុខមិងមាំង៖

សិស្សខ្ញុំ!មានទៅណា?ពួកគេចង់ ចូលមកសមក្នុងបន្ទប់ខ្ញុំយប់នេះ!

វ៉ៃវរហើយ!អត់បានទេ!(ស្ត្រីនោះតបដោយបើកភ្នែកធំៗ)

ភាគទី៤

ឪម៉ាបើកភ្នែកមូលក្លុំជាសញ្ញាងឿងឆ្ងល់។នាងមិនទាន់សួរទេ តែស្ត្រីនោះបង្ហាញអាការៈអន្ទះអន្ទែងហាក់ចង់ឆ្លើយប្រាប់បន្តិចមិនចង់បន្តិច។

មីង?មីងយ៉ាងម៉េចហើយហ្នឹង?ម៉្ងៃនេះ ខ្ញុំឆ្ងល់រហូតម៉ងហើយ!

ស្ត្រីមេអណ្តើកដែលពេញ ប្រៀបដោយភាពតានតឹងលើផ្ទៃមុខ ដឹងថាមិនអាចលាក់កំបាំងបានទៀត ក៏ស្ទុះទៅតោងដៃនាងហើយនិយាយតបវិញ៖

ឪម៉ាកូន!ពីពេលនេះទៅ ឯងទៅ ណាត្រូវគិតមុខក្រោយ!គឺ គឺថាកុំធ្វើអីតាមចិត្ត!

នៅពេលស្រស់ស្រីកាន់តែបើកភ្នែកមូលក្លុំ ស្ត្រី នោះពោលបន្ថែមភ្លាម៖

មីង មីងគ្រាន់តែខ្លាច លោកប្រុសសិទ្ធិគុណដឹងថា ដឹងថា យប់នេះឯងមិនមែននៅជាមួយលោកប្រុសរាម!

ស្រីស្រស់ភ្ញាក់ស្មារតីនាងយល់ពី អ្វីដែលស្ត្រីនេះព្យាយាមនិយាយហើយតែនាងបង្ហាញភាពមិន យល់ស្របភ្លាម៖

មីងចង់និយាយថា ថៅកែសិទ្ធិគុណរបស់មីងគេមិនអោយខ្ញុំរួចខ្លួនអញ្ចឹងហ្អី?

ស្ត្រីមេអណ្តើកងក់ក្បាលផ្ញក់ៗជំនួសចម្លើយ។នារីបង្ហាញម៉ូតចងចិញ្ចើមដោយមួហ្មង៖

មីងមិនមែនចង់និយាយថា ខ្ញុំត្រូវការ លោកប្រុសរាមរបស់ មីងតាមការពារគ្រប់ជំហាននៅលើកោះ បាលីនេះទេមែនទេមីង?

នាងក្រោកឈររៀបរយសំលៀកបំពាក់ទាំងទឹកមុខល្ងើយនិងហ្មងសៅរួចទាញកាបូបបម្រុងចាកចេញព្រមទាំងបោះសម្តីចុងក្រោយ៖

ស្អែកបុប្ផាអាស៊ីចាប់ផ្តើមហើយ!ខានស្អែកខ្ញុំនឹងនាំ ក្រុមកិន្នរីហ្វេសិនទៅភ្នំពេញវិញ!មីងមិនបាច់ព្រួយទេ!ខ្ញុំអាចមើលថែខ្លួនឯងបាន!

នាងនាំកាយល្វតល្វៃចេញទៅតែត្រូវអ្នកស្រីទាញដៃមកវិញ។

ឪម៉ា!(គាត់ហៅតិចៗ)

ទឹកមុខព្រួយបារម្ភនិងសម្តីឃាត់ខ្លីពីរម៉ាត់ធ្វើអោយតរុណីយើងមានអារម្មណ៍ថាស្មុគស្មាញណាស់។នាងបែរក្រោយនិយាយទាំងធុញទ្រាន់៖

មីងកុលាប!ខ្ញុំតឹងចិត្តរឿងមីងពេញមួយថ្ងៃហើយ!មីងមានរឿងអី?មីងមានការអីខ្លះដែលលាក់កំបាំងខ្ញុំ?ហើយវាទាក់ទងអីជាមួយខ្ញុំខ្លះ?ខ្ញុំធុញណាំមីង!ខ្ញុំធុញមែន!ដូចអំបាញ់មិញអញ្ចឹងនៅខាងលើ មីងខ្លាចពួកគេនោះដល់ថ្នាក់គេវាយយ៉ាងហ្នឹងហើយមីងនៅទ្រាំនៅលូនអង្វរគេ?ខ្ញុំកោតមីងណាស់?មីងធ្វើអញ្ចឹងទៅកើត!ធ្វើដូចយើងអត់មែនជាមនុស្សដែរអញ្ចឹង?

នាងបញ្ចប់សម្ដីទាំងទឹកមុខឈឺចាប់។

វាចាស្ត្រីឈ្មោះកុលាបលាន់មកស្មើថៃសកាត់ផ្ដាច់សកម្មភាពមួយហ្នងរបស់នាង

ឯងត្រូវតែជួយមីងណ៎ាឪម៉ា!

នារីសើចយឹកៗទាំងទឹកភ្នែកស្មើរស្រក់ធ្លាក់។នាងក្រពាត់ដៃទ្រាំទប់ទឹកភ្នែកណាស់ទម្រាំអាចនិយាយតបទៅកាន់គូសន្ទនា៖

ជួយទៅអោយគេប្រមាថមើលងាយជាមួយមីងដែរអញ្ចឹងអ្ហេះ!?

នាងចាកចេញទៅដោយមិនរង់ចាំអោយគាត់បានឆ្លើយតបតែស្ត្រីនោះរហ័សដូចបានប្រុងប្រៀបរួចហើយគាត់ស្ទុះអោបនាងជាប់ទាំងយំសស្រាក់។

ឪម៉ា!លើកនេះបើកូនមិនជួយមីង មីងស្លាប់ហើយឪម៉ា!មីងប្រាកដជាស្លាប់!

ស្ត្រីស្គាល់តែប្រាក់ទ្រហោយំង៉ោងក្រោមលង្វែកទ្រូងនាង ឪម៉ានឹកឃើញភ្លែតដល់គ្រាមួយកាលពីមុននេះ៦ខែ ដែលនាងបានស្កាត់ទៅរកគាត់។នាងបានស្រក់ទឹកភ្នែកហើយលើកដៃសំពះគាត់ ថានាងត្រូវការប្រាក់ចំនួនគួរសមដើម្បីព្យាបាលជំងឺដ៏ធ្ងន់របស់ប្អូនប្រុស។ចំនួនទឹកប្រាក់មិនច្រើនក៏មិនតិចជាទឹកប្រាក់ដែលនាងដូរទាំងជីវិតទៀតក៏រកមិនបានដែរក្នុងកាលៈទេសៈដ៏លំបាកនោះ។ប៉ុន្តែទីបំផុតគាត់រកមកអោយនាងបានសម្រេចមែន ដែលធ្វើអាយនាងចាំបាច់ត្រូវលះបង់ភាពជានារីបរិសុទ្ធកាយ ក្នុងលក្ខខណ្ឌតបស្នង។

នាងសង្កត់ចិត្តនិយាយស្រាលៗ៖

មានរឿង អី!មីងនិយាយទៅ!ខ្ញុំជួយមីងជាចុងក្រោយ!តែមិនមែនទៅជាមួយសិទ្ធិគុណទេណ៎ាមីងស្ដាប់អោយច្បាស់!

ស្ត្រីនោះងើបមុខហើយរុញនាងអោយទៅអង្គុយលើពូក វិញ។នៅ ពេលគាត់ដាក់បង្គុយចុះទន្ទឹមនាងហើយ គាត់ចាប់សម្លឹងភ្នែកនាងទាំងសងខាងក្នុងន័យអង្វរករ៖

ឪម៉ា!នៅទីនេះត្រូវគិតមុនធ្វើអ្វីមួយ។ ត្រូវក្រែងចិត្តលោកប្រុសរាមណ៎ា !យកល្អមុនទៅ ណាមកណា ធ្វើ អីជាមួយអ្នកណាត្រូវពិភាក្សាជាមួយមីងសិន!

ឪម៉ាចងចិញ្ចើម។ឈ្មោះបុរសនោះធ្វើអោយនាងវិលមុខតែនៅចាញ់ឃ្លាចុងក្រោយនេះទេ។ នាងតបសួរ៖

មីង!ខ្ញុំខ្លាចចិត្តគេធ្វើអី?គេដោយគេ យើងដោយយើងណ៎ាមីង!រឿង ចាស់ យើងទូទាត់គ្នាអស់ហើយមែនទេ?គេជួយខ្ញុំ តែគេក៏បានអ្វីៗដែលគេចង់បានហើយដែរមែនទេមីង?

អ្នកស្រីកុលាបឈ្ងោកមុខជ្រប់តែគាត់តោងដៃនាងជាប់៖

តាមពិត...

នារីបន្តរដោយរអាក់រអួល៖

តាមពិតអីទៅ?គេដៀលយើង ថាយើងលក់ខ្លួនណា មីង មីងមានលឺ អត់?គេថាម៉េចខ្លះ អំបាញ់មិញនេះ?មីងទៅតស៊ូលុតក្រាបគេធ្វើ អី?មីងត្រូវការលុយប៉ុន្មានទៀតបានឆ្អែត?

មិនមែនអញ្ចឹងទេឪម៉ា(ស្ត្រីលូកមាត់កាត់)លោកប្រុស រាមមិនមែនអាក្រក់ដូចឯងគិតទេ!

នៅពេលនាងម៉ូដែលសើចឃ្មឹះចំអកសម្តីកាន់ជើងរបស់គាត់មីងកុលាបព្យាយាមពន្យល់នាងភ្លាម៖

លោកនិយាយចេញមកដោយសារតែខឹងប្រចណ្ឌហ្នឹងហើយ!លោកខ្លាចឯងទៅនៅជាមួយថៅកែសិទ្ធិគុណ!

យុវតីនៅស្ងៀម តែនាងហូរទឹកភ្នែកព្រិចៗរួចឆ្លើយតបអួលអាក់៖

ខ្ញុំធ្លាប់ទៅធ្វើអញ្ចឹងជាមួយ គេ គេ ក៏មានសិទ្ធិគិតអញ្ចឹងហើយ!គេគិតថាខ្ញុំខ្លាចអីនឹងធ្វើអញ្ចឹងជាមួយប្រុសផ្សេងទៀត ដូចដែលមីងធ្លាប់ប៉ងយកខ្ញុំទៅអោយអ្នកនេះអ្នកនោះអញ្ចឹងដែរ!

មីងកុលាបគ្រវីក្បាល៖

លោកប្រុសរាមមិនដែលគិតថានាងលក់ខ្លួនទេកូន!

ស្រីរូបល្អលើកដៃជូតទឹកភ្នែកហើយវាចាមួយៗ៖

មនុស្សស្រីដែលយកប្រាក់គេ ហើយទៅនៅជាមួយគេអស់មួយយប់ បើមិនលក់ខ្លួនតើជាស្អីវិញទៅ?មីងចាំបាច់មកនិយាយអោយពីរោះដែរ?

ដឹងថាបើមិននិយាយការពិតគឺមិនបានសុខ ទៀត ស្ត្រីមេអណ្ដើកចាំបាច់ត្រូវបកស្រាយពន្យល់នាងអោយអស់សេចក្ដី។គាត់បន្តភ្លាម៖

កាល ហ្នឹងគឺមីងកុហកឯង!លោកប្រុសរាមមិនបានត្រូវការខ្លួនប្រាណឯងទេ ប្រាក់នោះគឺលោកព្រមជួយឯងដោយស្មោះ!

ឪម៉ាងាកសម្លឹងមុខស្ត្រីដែលនៅចំពោះមុខខ្លួន។នាងកំពុងគិតថាតើគាត់គាំងសតិដោយសារគេវាយ ដំរីមួយគាត់ឆ្កួតមែន។នាងគិតក្នុងចិត្តម្នាក់ឯងស្ងាត់ៗ។"អញ្ចឹងបុរសដែលខ្ញុំត្រូវនៅកំដរគេទាំងគ្មានមនោសញ្ចេតនាអ្វីបន្ដិចនោះជានរណាវិញមីងកុលាប?"

ឃើញនាងមិនចេញស្ដីស្ត្រីមេអណ្ដើកពោលបន្តភ្លាម៖

គ្រួសារគេត្រឹមត្រូវមានពូជមានពង្ស គេមិនទៅធ្វើអញ្ចឹងទេឪម៉ា តែមីងកុហកឯងហើយ មីងក៏..ក៏កុហកលោកប្រុសរាម...!

ឪម៉ាដៀងភ្នែករិះគិតក្នុងពេលមីងកុលាបនិយាយបន្តជាប់មករដឹក៖

មីងសុំខ្ចីប្រាក់គេអោយឯង ជាកិច្ចសន្យាខ្ចីប្រាក់ធម្មតា តែមីងប្រាប់គេថា កូន ឯងពេញចិត្តនឹងសងគុណគេ គឺថាកូន ឯងគ្មានលទ្ធភាពសង គេ ។យប់នោះគឺកូនធ្វើចំពោះគេដោយពេញចិត្ត ទេ បានជាមានរឿងហ្នឹងកើតឡើង។

ឪម៉ាយល់ ហើយ។នាងគិតថាស្ត្រីនេះកំពុងព្យាយាមនិយាយល្អអោយរាមនរិន្ទក្នុងបំណងថ្មីអ្វីមួយ។នាងពោលសួរវិញផ្ដើនគាត់៖

អញ្ចឹង?

គាត់ងក់ក្បាល។នាងពោលចំអកឡកឡឺយ៖

ប្រុសម្នាក់មិនដែលស្គាល់ខ្ញុំហើយនៅសុខៗមកជួយលុយខ្ញុំច្រើនដល់ម្លឹង?ម្យ៉ាងទៀតគេ...គេ..មីងថា..គេមិនចង់ទេ តែយប់នោះបានកើតឡើងហើយមែនទេ ?បើមិន ចង់ម៉េចក៏មីងមកនាំខ្ញុំទៅអោយគេ មីងដឹងហើយថាដូចសម្លាប់ខ្ញុំទាំងរស់អញ្ចឹង!មីងដឹងហើយមែនទេ!ឥឡូវមកនិយាយល្អអោយគេទៀត!មីងមានល្បិចអីទៀតមីងថាទៅ!?

ស្ត្រីនោះដាក់បង្គុយប៉ុកទៅលើដីដោយអស់សង្ឃឹម។គាត់និយាយរអ៊ូម្នាក់ឯង៖

មីងប្រើល្បិចលើឯងមែនឪម៉ា!តែមិនមែនឥឡូវទេ!តាំងពីថ្ងៃហ្នឹងម្លេះ!បើលោកប្រុសរាមដឹងមីងច្បាស់ជាចប់ហើយ!មីងត្រូវជាប់គុកមិនខាន!

ឪម៉ាធុញ ណាស់ហើយតឹងចិត្តណាស់ព្រមទាំងយល់ថារំខានណាស់តែសភាពរបស់មីងកុលាបនៅពេលនេះធ្វើអោយនាងចេះតែសង្ស័យថាគាត់ដូចជាមិនមែនកំពុងធ្វើពុតទេ។នាងបែរជាយកចិត្តទុកដាក់ជាងមុន ហើយសង្ខេញសួរ គាត់៖

ល្បិច អី!មីងនិយាយតាមសម្រួលមក និយាយអោយអស់មក!

កាលពីប្រមាណជា៣ខែមុននៅពេលអ្នកគ្រូម៉ូដែលដ៏ស្រស់ សោភាប្រកបដោយកេរ្តិ៍ឈ្មោះល្អស្អាតបរិសុទ្ធបានប្រឈមនឹងវិបត្តិក្នុងជីវិតនាងត្រូវបានគេនាំមកជួបអ្នកស្រី កុលាប។គាត់ដឹងថានាងត្រូវការប្រាក់មួយចំនួនក្នុងសភាពបន្ទាន់និងទាល់ច្រក។នាងចង់បានការងារក្នុងសង្គមសិល្បៈគ្រប់ប្រភេទដែលអាចអោយនាងរកបានក្នុងចំនួនដ៏ច្រើនគួរសមនោះប៉ុន្តែគាត់បានណែនាំនាងអោយទទួលជំនួយពីបុរសដ៏មានអំណាចនិងប្រាក់កាសហើយនាងចាំបាច់ត្រូវតបស្នងគេដោយកិត្តិយសរបស់ស្រីក្រមុំ។

នៅក្នុងសង្គមមួយដែលអំពើជួញដូរមនុស្សត្រូវ បានហាមឃាត់ដោយច្បាប់ប៉ុន្តែអ្នកមានប្រាក់មានអំណាចជាច្រើននៅតែ អាចលួចលាក់បំពានកេង ចំណេញលើ ភាពទ័ល ក្ររបស់ នារីរូបស្អាតជាច្រើននោះ ឪម៉ាបានយល់ព្រមទទួលលក្ខខណ្ឌរបស់មីងកុលាបទាំងកាយរស់បេះដូងស្លាប់។

នាងបានជួបរាមនរិន្ទតាមការរៀបចំទុករបស់ស្ត្រីនេះ ហើយក៏បែកពីគេជារៀងរហូតចាប់តាំងពីរាត្រីនោះសូម្បីតែទំនាក់ទំនងបន្តិចក៏គ្មាន។នៅ ថ្ងៃនេះនាងបានវិលមកជួប គេវិញដោយឥត ព្រាងទុកដោយរំលឹកមកវិញអោយស្រី ស្រស់នូវភាពអា ម៉ាសនិងអពមង្គល។

ទើបតែពេលនេះដែលស្រ្តីអ្នកជួញដូរមនុស្សដឹងថាប្រសិនបើរឿងពិតត្រូវបានថ្លោះធ្លោយ ដោយ ប្រការណាមួយគាត់នឹងត្រូវជាប់ ទ្រុងសារិកាដូចដែលរាមនរិន្ទបានគំរាមរួចមកហើយកាលនៅជាន់ខាងលើ។

ការពិតអ្វីទៅ?

គឺ ការពិតពាលស៊ីពាលដែលរវាងមនុស្សបី នាក់មានតែគាត់ម្នាក់គត់ដែលបានដឹងនឹងរៀបចំគម្រោងយ៉ាងស្អាតរួចមកហើយ។

គាត់បានទៅ ជួបរាមនរិន្ទហើយរ៉ាយរ៉ាប់ពីគ្រូ របាំ និង ជា នារី ម៉ូដែលរូប ស្អាតកំព្រើកំព្រាម្នាក់ដែលគ្មានឪពុកម្តាយជាទីពឹងនឹងកំពុងរស់តែលតោលក្នុងសិល្បៈ។គាត់ ថានាងជានារីបរិសុទ្ធ ល្អមានភាពប្រាកដប្រជាប៉ុន្តែកំពុងរង វិបត្តិព្រហ្មលិខិតដែលត្រូវការស្វែងរកជំនួយព្យាបាលជំងឺធ្ងន់របស់ប្អូនប្រុស។ រាមនរិន្ទត្រូវ បានអង្វរករអោយទទួលទំនុកបម្រុង នាងដោយសប្បុរសបើមិនដូច្នោះទេនាងនឹងត្រូវជាន់ ឈ្លីដោយបុរសអាក្រក់ផងទាំងឡាយមិនខាន។ ភាពប៉ិនប្រសប់របស់ស្រ្តីមេអណ្តើកបានទាក់ទាញអោយបុរសអភិជនចាប់អារម្មណ៍ចំពោះករណីជួយសង្គ្រោះមួយនេះ ហើយ គេបានសម្រេចចិត្តផ្តល់អោយនាងនូវចំនួនប្រាក់តាមដែលនាងត្រូវការ ដោយក៏មិនដែលគិត ថានឹងធ្វើអាយជីវិតនាងវិនាសហិនហោចដោយសារលក្ខខណ្ឌតណ្ហាមួយពេលដែរ។

"មីងត្រូវប្រាកដថា កេតឌីម៉ានឹងរស់នៅដោយថ្លៃថ្នូរក្នុងសិល្បៈ!បើមិនអញ្ចឹងទេ មីងមានរឿងជាមួយខ្ញុំ!"សម្តីរបស់រាមនរិន្ទនៅថ្ងៃនោះបានធ្វើអោយស្រ្តីចំណាស់បានជោគជ័យពាក់កណ្តាលព្រោះគាត់ដឹងថាគាត់បានមករកត្រូវគោលដៅ។ប៉ុន្តែប៉ុន្មានថ្ងៃក្រោយមកគាត់បានឈានទៅរកផែនការទី២ដោយបានមករកបុរសអភិជនសាជាថ្មីហើយពន្យល់ប្រាប់គេថា ធីតារូប ល្អមានភក្តីភាពតបស្នងសងគុណអ្នកសង្គ្រោះនាងដោយ ស្មោះ ហើយសំណូមពរអោយបុរសនេះទទួលយកទឹកចិត្តស្វាមី ភក្តិរបស់ នាង។

ផ្កាស្រស់ ក្រពុំត្រូវបានផ្សំផ្គុំទៅអោយបុរសមានឋានៈទៅតាមគម្រោងការចុងក្រោយ ដែលជាល្បិចបូកបន្ថែមអោយរាមនរិន្ទនូវភារៈទទួលខុសត្រូវក្នុង ការទ្រទ្រង់ជីវិតរស់នៅប្រចាំថ្ងៃរបស់នាងជារៀងរហូតមក។ភាគីបុរសយល់ថា នារីយល់ព្រមតបស្នងការស្រលាញ់ជាការសងគុណ ឯនារីយល់ថា នាងត្រូវបានគេទារអោយសងតាមទំហំទឹកប្រាក់ដែលគេបានចំណាយ។

ប៉ុន្តែដែលសំខាន់គឺបុរស នោះមិនដែលមករកនាងជាលើកទីពីរទេចាប់តាំងពីពេលនោះ មក ដោយសារនាងគ្មានចំណែកនៅ ក្នុងបេះដូងគេ។តើអ្នកណាជា អ្នកទទួលផល?

ឪម៉ាទន់ដៃជើង  នាងល្ងិតល្ងៃនិមិត្តស្តាប់ចប់ដំណើររឿងនេះ។នាងសួរឡើងទាំងល្វើយ៖

មីង?មីងយកលុយគេរហូតមកមែនទេ?មីងអាងអីដែលមីងហ៊ានធ្វើអញ្ចឹង?

ស៊ូត!(ស្ត្រីនោះលើកដៃបង្ខំអោយនាងទម្លាក់សំឡេងដោយសារខ្លាចថាមានមនុស្សស្តាប់លឺ)

មីងខុសហើយឪម៉ា!មីងសុំទោស!មកពីមីងល្មោភល្បែង !មីងចាញ់អស់!មីងជំពាក់គេជុំទិស មីងអស់ផ្លូវដើរបានជាមីងហ៊ានកុហកលោកប្រុសរាម!

ឪម៉ាដឹងហើយ ថាហេតុអ្វីបានជាស្ត្រីនេះខ្លាចរាមនរិន្ទដល់ម្លឹងហើយហេតុអ្វីបានជារាមនរិន្ទ ហ៊ានមកហួងហែងការពាររឿងផ្ទាល់ខ្លួនរបស់នាង។មកពីគេគិតថានាងជាមនុស្សរបស់គេនៅ ឡើយ ហើយច្រឡំថានាងស្រលាញ់គេ នឹងព្រមនៅជាមួយគេរហូតមក។ទោះជាគេមិនធ្លាប់ ដែលបានមករកនាងទៀតក៏ដោយតែ គេនៅឧបត្ថម្ភនាង ជានិច្ច មានន័យថានាងនៅតែជា កូនបក្សីក្នុងកណ្តាប់ដៃគេនៅឡើយ។

នាងគ្រវីក្បាលតតាត់៖

អត់ទេមីង!អត់ដាច់ខាត!ខ្ញុំអត់ដឹងលឺ ទេ!គេដោយគេ ខ្ញុំដោយខ្ញុំ!មីងស្តាប់អោយច្បាស់!រឿង មីងជាមួយគេមីងដោះស្រាយអោយស្រួលទៅ!មីងអ្នកយកប្រាក់គេ មីងដោះស្រាយជាមួយគេ ខ្លួនឯង!កុំអោយទាក់ទងជាមួយខ្ញុំទៀត!

នាងក្រោករត់ចេញទៅ តែស្ត្រីនោះរត់ទៅតាមដល់មាត់ទ្វារហើយលូកដៃខ្ទប់សោជាប់មិនព្រម អោយនាងមួលចេញឡើយ។

ឪម៉ា!ឯងកុំដាច់ចិត្តពេក!មីងក៏មិនដឹងថាគេមកបាលីដែរ ទេ!តែប៉ុន្មានថ្ងៃ ហ្នឹង!ឯងតាមចិត្តគេ ប៉ុន្មានថ្ងៃហ្នឹងទៅកុំអោយគេដឹងរឿង បើគេដឹងរឿង....

ឪម៉ាស្រែកតបវិញដោយទឹកភ្នែក៖

តាមចិត្តគេ?កោតតែមីងនិយាយអីក៏ស្រួលៗម៉េះ មើលតែបាយឡុកបាយឡអញ្ចឹង!នៅមិននៅមីងធ្វើល្បិចល្បែងយកលុយគេរាប់ខែ ហើយយកឈ្មោះខ្ញុំទៅលោប!មីងគិតទៅមើល៍ ខ្ញុំនៅល្ងង់ជួយមីងទៀតដែរ?

ស្ត្រីចំណាស់នៅតែចចេស ៖

តែគេជាមនុស្សល្អ!គេមានប៉ះពាល់ឯងទៀតឯណា?ច្រើន ខែមកនេះ!ឯងមានខាតបង់អីឌីម៉ា! ឯងសំណាងហើយកាលហ្នឹងមីងរកគេអោយជួយឯង!បើប៉ះប្រុសផ្សេងវិញ ឯងទក់សាច់បាត់ហើយ !

នាងសើចទាំងទឹកភ្នែកគឺសើចដោយហួសចិត្ត៖

ខ្ញុំត្រូវអរគុណមីងទៀតមែនទេមីងកុលាប?

ស្ត្រីនោះដឹងថានាងខឹងណាស់ដែលលឺថាសេរីភាពខ្លួនកំពុងគ ម្រាមកំហែង។គាត់លើកដៃសំពះអង្វរនាងតែម្តង៖

មីងសុំទោសឯង!មីងសុំទោសមែន!ឯងគិតថា មីងធ្លាប់ជួយឯង!បើឯងអោយលោកប្រុស រាមដឹងថាមីងយកលុយគេហើយបោកប្រាស់គេទទេៗ មីងចប់ហើយឌីម៉ា!

គេតឌីម៉ាតាំងចិត្តលែងខ្វល់ចំពោះស្ត្រីល្មោភ ប្រាក់។នាងរុញគាត់ទៅម្ខាងរួចបើកទ្វារចាកចេញ។

ភាគទី៥

មកដល់ជាន់ខាងក្រោម នាងឃើញមនុស្សម្នារួមទាំងបុគ្គលិកបម្រើការនៅទីនេះផងសម្លឹងមកនាងដោយទឹកមុខចម្លែក។

នាងយល់ថា កាលពីល្ងាចនាងបានធ្វើអោយមានបញ្ហាមួយចំនួនរហូតដល់មានការបោកចានកែវនៅក្នុងភោជនីយដ្ឋានបន្ទាប់មកនាងត្រូវឡើងទៅបន្ទប់ខាងលើតាមរាមនរិន្ទទៀត គេមើលមកនាងច្បាស់ជាគិតពីរឿងអាស្រូវច្រើនជាងរឿងល្អ។កាន់តែគិតនាងរឹតតែមួរក្នុងចិត្តហើយប្រឹងដើរអោយរឹតតែញាប់ជាង មុនចាកចេញពីទីនោះកាត់តាមសួនច្បារឆ្ពោះទៅកាន់

តំបន់មាត់ឆ្នេរដើម្បីស្វែងរកផ្លូវកាត់ សំដៅទៅរកទីសំណាក់របស់ខ្លួនបានកាន់តែឆាប់កាន់តែល្អ។

ស្បែរាត្រីក្រាលដណ្តប់លើតំបន់ឆ្នេរដ៏ល្បីបណ្តាច់របស់ឥណ្ឌូណេស៊ី ជាតំបន់ទេសចរក្នុងក្តីស្រមៃរបស់បណ្តាជន និងជាគោលដៅនៃក្រុមអភិជនពិភពលោកទាំងឡាយ។

នៅចប់តាមផ្លូវឌីម៉ានឹកថា ពិធីបង្ហាញម៉ូតនឹងចូលមកដល់នៅថ្ងៃស្អែក នាងមិនទាន់ទាំងបានធ្វើការបង្វឹកសមក្រុមផង បែរជាវរល់មកទាក់ទាមជាមួយរឿងរ៉ាវ ដ៏គ្រោតគ្រាតល្មមអោយរំខានចិត្ត។ដូច្នេះចំពោះ មុខ ត្រូវតែធ្វើ ម៉េចអោយក្រុមការងាររបស់ខ្លួនបំពេញការងារអោយបានល្អ នឹងអាលឆាប់ចប់តាមគម្រោងព្រមទាំងអាចវិលត្រឡប់ទៅកាន់ប្រទេសវិញ។

តរុណីរាងរាវធ្វើដំណើរតែឯងកាត់តាមបរិវេណឧទ្យានGingerដ៏ស្រស់បំព្រងក្រោមភាពប្រែប្រួលកាន់តែត្រជាក់ទៅៗនៃហេមន្តរដូវ។

គន្ធពិដោរដ៏ក្រអូបប្រហើរនៃបុប្ផាជាតិGingerចំរុះពណ៌បានធ្វើអាយអោយធីតារសាយចេញពីទុក្ខកង្វល់ ដោយងើយស្រូបយកភាពស្រស់បំព្រងកណ្តាលធម្មជាតិដើម្បីទទួលយកភាពធូរស្រាលអោយរាងកាយប៉ុន្តែសំ រិបជើងស្រាលៗលាន់មកពីទិសខាងក្រោយធ្វើអោយនាងប្រមូលអារម្មណ៍មកវិញ។

ភាពតឹងតែងនិងភ័យ ព្រួយរត់រសឹបមកឃាឃីប្រាណធីតាសារជាថ្មី។សោតាទាំងទ្វេផ្ទៀងស្តាប់ ជើងទាំងគូកាន់តែស្វាហាប់បោះជំហានទៅមុខលែងហ៊ានបែរ ក្រោយ។

"មានមនុស្សដើរតាមយើងច្បាស់ណាស់"នាងគិតដោយពិភាល់។

ទោះបីក្រឡេកឆ្វេងស្តាំនាងឃើញមានភ្ញៀវទេសចរខ្លះកំពុងជិះកង់និងរត់ត្រឹកៗហាត់ប្រាណដោយអន្ទើក៏ដោយ នាងនៅតែចាប់អារម្មណ៍ចង់ដឹងថាអ្នកនៅពីខាងក្រោយជាអ្នកណា?គេតាមនាងដោយចេតនាវីមួយមានការភ័ន្តច្រឡំអ្វីម្យ៉ាង?

នាងងាកក្រោយភ្លែតសម្លឹងទៅបុរសពីរ នាក់ក្នុងសំលៀកបំពាក់ធម្មតា ប៉ុន្តែដែលឃើញមុខកាលណានាងចាប់ភ័យព្រួយ។ទោះបីមេឃចាប់ផ្តើមងងឹត តែពន្លឺ ភ្លើងគោមអមលំអតាមជ្រុងផ្លូវនានានៃឧទ្យានផ្កាបានធ្វើអាយឌីម៉ាអាចចំណាំ មុខអ្នកទាំងពីរបានថាជាអង្គរក្សរបស់រាម

នរិទ្ធដែលនាងបានជួបកាលពីល្ងាចច្បាស់លាស់ទោះបីគេលែងប្រើសំលៀកបំពាក់ដដែលហើយក្តី។

នារីស្លុតចិត្ត។នាងបែរមកវិញហើយអោបកាបូបជាប់ទ្រូង។ដើរត្រឹកៗទៅមុខបណ្តើរនាងគិតបណ្តើរ។

"ពីរនាក់នោះតាមយើងតាំងពីពេលណាមក?តើគេជួបនាងនៅទីនេះជា រឿងចៃដន្យរឺមួយជាគម្រោងការអ្វី?"

នាងកាន់តែដើរញាប់កាលណាត្រចៀកកាន់តែលឺសំ រិបជើងជនទាំងពីរតាមមកយ៉ាងកៀក។មិនអាចធ្វើជាមិន ដឹងខ្លួនបានទៀតទេ នារីអោបកាបូបរត់រឹងឆ្លងផ្លូវចូលទៅ ក្នុងសណ្ឋាគាររបស់នាងដែលនៅទិសខាងស្តាំប្របមាត់ផ្លូវ។

នាងរត់ឡើងជណ្តើរនិងរើសោរចាក់ចូលក្នុងបន្ទប់ទាំងហត់គឃូសរហូតដល់ទ្វារ បិទវិញលាន់សូរ គ្រឹបទើបនាងធូរចិត្តមកវិញ។

ឪម៉ាទម្លាក់ខ្លួនទៅលើសាឡុងរួចបិទ ភ្នែកទាំងសងខាងបំបាត់ភាពនឿយហត់ហួស។ស្នូរទូរស័ព្ទលាន់មករឹងៗ ធីតារូប ល្អបើកភ្នែកមកវិញដោយភិតភ័យ។នាងដកដង្ហើមយូរធូរចិត្តមកវិញព្រោះឃើញខ្លួនកំពុងជ្រកក្នុងទីប្រកបដោយសុវត្ថិភាពនៅឡើយ។

នាងលើកទូរស័ព្ទមកមើល ឃើញព័ត៌មានលើScreenបប្ញូរមាត់ផុស ឡើងនូវស្នាមញញឹមស្រស់ចិញ្ចាច។

តាមពិតគឺនាងកំពុងធ្វើតាមអំណាចនៃបេះដូងដែលទទួលយកសញ្ញាសុខសាន្តនៅពេលបានលើឧបករណ៍បញ្ជូនសំឡេងមកផ្អឹបនឹងត្រចៀក។នាងបន្លឺមុនពេលលឺសំឡេងអ្នកCalledមកទៅទៀត៖

បងKen!

ស្នូរសំណើចស្រាលៗរបស់បុរសឈ្មោះKenលាន់លឺមកវិញជំនួសអោយសម្តីស្វាគមន៍។ធីតាបង្ហាញម៉ូតបង្ហាញភាពស្រស់ថ្លាតាមពន្លឺ ភ្នែកហើយពោលទៅកាន់គេនូវប្រយោគទី២៖

បងនៅឯណា?

ស្នូរសញ្ញាកណ្ដឹងទ្វារបន្ទប់ធ្វើអោយនាងប្រែទៅជាបើកភ្នែកគ្រលួង។សូរស័ព្ទបុរសនៅឯចុងម្ខាងនិយាយមកកាន់ម្ចាស់ ស្រីនៃបន្ទប់នេះនូវប្រយោគដំបូងបង្អស់៖

ទៅបើកទ្វារទៅកេតឌីម៉ា!

ប្រកបដោយទឹកមុខងឿងឆ្ងល់ តែបន្ទាប់មកក៏ក្លាយទៅជារំភើបរីករាយសន្សឹមៗ ។នារីក្រោកលូតលៃ្វទៅក្បែរទ្វារហើយអើតសម្លឹងទៅក្រៅតាមកូនប្រឡោះមូលតូច។នាងអោនមកវិញទាំងលូកដៃមួលសោបើកទ្វារដោយស្នាមញញឹមប្រិមប្រិយ។

ផ្កាSaffron Crocus ពណ៌ស្វាយស្រោលរៀបចំដោយផ្ចិតផ្ចង់លើ ផើងគ្រីស្តាល់ល្អ វិចិត្រត្រូវបានហុចមកចំពោះមុខកេតឌីម៉ាធ្វើអាយនាង បើកភ្នែកមូល ក្រឡង់ស្វាគមន៍អំណោយដែលតំណាងនូវមនោសញ្ចេតនាស្នេហា ដ៏ជ្រាលជ្រៅនេះរហូតភ្លេចគិតថាបុរសអ្នកលើកផើងបុស្បាកំពុងញញឹម ស្រស់តាមអារម្មណ៍រំភើបរបស់នាង។

សូមចុះហត្ថលេខាទទួលផង!

ភាសាអង់គ្លេសរបស់បុរសឥស្លាមបានដាស់នារីខ្មែរអោយភ្ញាក់ ចេញពីសុបិនសួគ៌ា។នាងញញឹមតបទៅកាន់បុរសអ្នកផ្ដល់សេវាហើយទទួលប៊ិចពីគេមកចុះហត្ថលេខាទទួល។ស្រីស្រស់វិលត្រឡប់ចូលមកវិញជាមួយអំណោយស្រស់បំព្រងក្នុង ដៃក្នុងពេលដែលសំឡេងម្ចាស់ទូរស័ព្ទដែលសំងំស្ងៀមអស់មួយខណៈនោះលាន់មកសារជាថ្មី៖

សង្ឃឹមថាអូនពេញចិត្ត!

កេតឌីម៉ាដៃ ម្ខាងដាក់អំណោយទៅលើកកូនតុតាំងដៃម្ខាងទៀតនិយាយតបជាមួយម្ចាស់វត្ថុ៖

ចាស៎ ពេញចិត្តណាស់បងKen !តែ តែវាថ្លៃណាស់ បងKenទិញផ្កាSaffronបានពីណាមកហើយបញ្ជូនមកដល់បាលីទៀត?

បុរសមិនបង្ហាញ រូបនៅតែសើចស្រាលៗទាក់ចិត្តនារីដែលកំពុងលង់ទៅក្នុងមនោសញ្ចេតនារបស់ខ្លួន។គេនិយាយបន្ត៖

ផ្កាល្អ សមនឹងស្រីស្អាតហើយ!

សម្ដីគេខ្លីៗតែបានធ្វើអោយស្រស់ស្រីឌីម៉ាស្លាប់ចិត្តស្រេចទៅហើយ។ដោយអំណាចនៃសេចក្ដីស្នេហា វាចាទាំងឡាយរបស់គេបានធ្វើអោយនាងចង់ស្ដាប់ហើយស្ដាប់ទៀតដូច្នោះទើបបានជាស្រី ស្រស់មិនទាន់ឆ្លើយតបអ្វីទៅវិញនៅឡើយបានត្រឹមញញឹមដាក់ផើងផ្កាពណ៌ស្វាយដែលជាជំពូកផ្កាដ៏កម្ររបស់ពិភពលោក។នរៈឈ្មោះKenបន្លឺបន្ត៖

ល្មមឈប់ញញឹមទៅ!កុំភ្លេចអាពីរ នាក់ដែលនៅចាំយាមខាងក្រោម !ប្រយ័ត្នវាដឹងក្លាយជារឿងធំ!

ស្នាមញញឹមកេតឌីម៉ារុះរោយនិមិត្តតែនឹកឃើញដល់បុរសកង អង្គរក្សពីរ នាក់ដែលតាមនាងកាត់តាមសួនច្បាររហូតមកដល់ទីនេះ។

នាងរត់ទៅរកបង្អួចរួចសម្លឹងចុះទៅជាន់ខាងក្រោម។តរុណីប្រទះឃើញមនុស្សក្រោមបង្គាប់របស់រាមនរិន្ទកំពុងគ្របពីក្រៅដោយអាវរងាក្រាសឃ្មឹកហើយនាំគ្នាដើរចុះឡើងនៅពីមុខភ្លោងទ្វារធំរបស់សណ្ឋាគារ។

នាងកើតភាពទោមនស្សទន្ទឹមនឹងពេលបុរសម្ចាស់ ទូរស័ព្ទបន្តនិយាយមកស្រាលៗ៖

ស្រី ស្អាតរបស់បងមានមន្ត ស្នេហ៍ដល់ ថ្នាក់អោយរាមនរិន្ទជ្រួលច្របល់ចៃក មនុស្សមកតាមហួងហែងទៀតហ្ន!

នារីថយមកអង្គុយលើគ្រែដោយទឹកមុខស្រពោន។មិនទាន់ឆ្លើយតបទៅកាន់បុរសកំពូលដួងចិត្តវិញផង នាងស្រាប់តែនឹកឃើញដល់រឿងផ្សេង។នាងសើចចិញ្ចាចដាក់ឧបករណ៍បញ្ជូនសំឡេងនិយាយទៅកាន់គេ៖

បងKenនៅបាលីមែនទេ?បងKenនៅឯណា?

ប្រសិនគេមិននៅទីនេះម៉េចក៏ដឹងសូម្បីតែស្រមោលនាងអញ្ចឹងនោះ?នេះជា អ្វីដែលកេតឌីម៉ាកំពុងតែគិតប៉ុន្តែនាងមុខតែខក បំណងព្រោះចម្លើយគឺផ្ទុយមកវិញ៖

បងចង់ទៅណាស់នៅពេលលឺថាមានពួកឃ្មុំបាក់ ស្លាបតាមចោមផ្កាSaffronរបស់បង ប៉ុន្តែបងទៅមិនទាន់បាន!

ខណៈដែលភាពស្រពាប់ស្រពោនគ្រប់ដណ្តប់លើកែវភ្នែកមាណវី។បុរសហៅតិចៗតាមឧបករណ៍បញ្ជូនសូរសម្លេង៖

ឱម៉ា!

ចាស!(ធីតារូប ល្អឆ្លើយមួយៗតបទៅកាន់ប្រុសស្នេហ៍ដោយសេចក្តីស្រលាញ់នឹករលឹកពេញបេះដូង)

បងផ្ញើបេះដូងទៅបាលី!ណ៎ា!(គេតបមកកាន់នាងមួយៗ)

អ្នកគ្រូម៉ូដែលរលីងរលោងទឹកភ្នែក។នាងអោបដៃទាំងគូរបញ្ជាប់ភាពរងាផ្លូវកាយ។មិនទាន់បានឆ្លើយថាយ៉ាងណាផង សូរសម្លេងទេវបុត្តកំពូល ស្នេហ៍បង្ហើរមកបន្ត៖

បងនឹកអូន!

គេដាក់ទូរស័ព្ទចាកចោលរាជិនីសម្រស់ដែលត្រូវ បានចោមរោមឆ្វៀលឆ្វាត់ដោយសត្វ កន្លង់នានា តែនាងបែរជាជាប់អន្ទាក់ស្នេហ៍ភូមរាមួយនេះដោយស្វាត់ៗតាំងពីពេលណាមកក៏មិនដឹង។នាងក្រោកដើរ សំដៅទៅរកផើងផ្កាដ៏ប្រណិតហើយលើកម្រាមចង្អុលខាងស្តាំរាប់បុប្ផានិមួយៗដោយប្រយ័ត្នប្រយែង។ត្រូវហើយគឺ៤៥ទងគត់។ជាចំនួនថ្ងៃដែលនាងបានស្គាល់បុរសម្ចាស់ ផ្កា។គេចាំសូម្បីតែរឿងនេះ បង្ហាញថាគ្មានថ្ងៃ ណាមួយដែលគេមិនបាននឹកដល់នាងទេ។នាងញញឹមដោយកក់ក្តៅទៅ រកស្រទាប់ផ្កា។

បងKenក្នុងបេះដូងអូន មានតែបងKenជានិច្ច!(នាងប្រាប់ខ្លួនឯងតិច!)

ស្នូរកណ្តឹងទ្វារលាន់ ឡើងសារជាថ្មី។ឱម៉ាដកក្រសែភ្នែកចេញពី វត្ថុអំណោយដោយសារនាងគិតថាប្រហែលជាសិស្សរបស់នាងនាំគ្នាឡើងមករកសមដែរហើយ។

នារីក្រោកទៅបើកទ្វារបន្ទប់ ដោយឥតរារែកតែនាងត្រូវសៅហ្មងវិញដោយសារស្ត្រីមេអណ្តើកបានបង្ហាញវត្តមានបន្ទាប់ពីគាត់ចាកចេញពីខ្យល់ដកដង្ហើមនាងមិនទាន់ដល់មួយម៉ោងស្រួលបួលផង។

ឱម៉ា!

គាត់ហៅឈ្មោះនាងទាំងញញឹមនៅពេលនារីវិលកាយចូលបន្ទប់វិញទាំងមិនសប្បាយចិត្ត។ ស្ត្រីនោះប្រឹងរួសរាយហើយលើកកញ្ចប់ចំណីអាហារដាក់រៀបទៅលើ តុមិនធ្វើខ្វល់អ្វីនឹងភាពទោមនស្សរបស់ម្ចាស់បន្ទប់ឡើយដោយគាត់ដឹងហើយថានាងនឹងមិនដាច់ចិត្តនិយាយអ្វីអសុរសទៅកាន់គាត់នោះទេ។

"មីងកុម្ម៉ង់បាយ ម្ហូបមក!ញ៉ាំបន្តិចទៅស្អែកត្រូវធ្វើការផង!"

ឌីម៉ាមិនទាន់ឆ្លើយតបថាយ៉ាងណាផង ស្រាប់តែស្ត្រី អ្នករកប្រាក់តាមវិធីទាន់សម័យលាន់មាត់ដោយភ្ញាក់ផ្អើល៖

"វ៉ោវ!ស្អីគេនេះ?Saffron?សណ្ឋាគារនេះដាក់ផ្កាហ្នឹងទទួលភ្ញៀវផងអ្ហាឌីម៉ា?"

នារីក្តាប់មាត់ងាក មុខចេញ ទន្ទឹមនឹង ពេលគ្រាប់ភ្នែកស្ត្រីជើងចាស់បង្វិលមួយជុំជាសញ្ញាត្រិះ។គាត់រត់មកក្បែរនារីបង្ហាញ ម៉ូតដែលកំពុងទាញបើកកញ្ចក់បង្អួចអោយក្លិនអាហារជះភាយទៅក្រៅ។

អ្នកណាទិញ ផ្កាថ្លៃយ៉ាង នេះអោយឯងកូន?

សូរសម្លេងមីង កុលាបដែលភ្ញាក់ផ្អើលក្រោមអំណាច ចិត្តលោភលន់សម្ភារៈនិយមធ្វើអាយកេតឌីម៉ាភ័យ ព្រួយ។នាងលើកដៃអោយ សញ្ញាគាត់អោយបន្ថយសំឡេងហើយលើកដៃចង្អុលទៅ ជាន់ខាងក្រោម។ស្ត្រីនោះអោនទៅ មើលតាមប្រឡោះដៃនាងក៏ឃើញអង្គរក្សពីរនាក់នោះកំពុងដើរចច្រប់ចុះឡើងដូចមនុស្សយន្តមិនចេះហត់នឿយ។

តាមពិតនាងចង់ប្រាប់អោយអ្នកស្រីកុលាបប្រយ័ត្នសម្តី កុំអោយលឺដល់គេនៅខាងក្រោយតែស្ត្រីនោះបែរជាយល់ផ្សេង។គាត់ញាក់ចិញ្ចើមសើច៖

លោកប្រុសរាមទិញអោយមែនទេ?

ឌីម៉ាហួសចិត្តតែនាងគិត ឃើញភ្លាមដែរថា បើចាក់បណ្តោយទៅ ប្រហែលជាស្ថានការណ៍ធូរស្រាលលឿនជាង។នាងងក់ក្បាលតិចៗរួចបង្វែងដាន៖

ក្រែងមីងទិញអីមកញ៉ាំមែនទេ!ខ្ញុំឃ្លានណាស់!

ស្ត្រីនោះបានដូច ចិត្ត។គាត់គិត ថានាងព្រមលេប អាហារប្រហែលជាចិត្ត នាងធូរស្រាលលែង គិតគុំក្អួននឹងគាត់ទៀតហើយក៏ប្រញាប់ប្រញាល់ផ្ដាប់ផ្ដុនរៀបចំបម្រើធីតាមិនអោយឃ្មើសចិត្តឡើយ។តាមពិតគាត់មិនដឹងទេ ថានាងកំពុងសប្បាយចិត្តនឹងរឿងផ្សេង។

អ្នកគ្រូវ័យក្មេងលើកស្លាបព្រាលេបអាហារបណ្ដើរឃ្លាំមើលកាយវិការស្ត្រីអ្នកជួញដូរស្នេហាបណ្ដើរ។នាងឃើញគាត់លូកដួសម្ហូបដោយថ្នមថ្នាក់ដាក់មកលើចាននាង ប្រកបដោយទឹកមុខញញឹមពព្រាយខុសពីពេលដែលគាត់ធ្វើឆ្មើងបានចិត្តដោយមានបុរសក្មេងឈ្មោះសិទ្ធិគុណនៅខ្នងបង្អែក។

នាងលួចគិតស្ងាត់ៗក្នុងចិត្ត៖

មនុស្សមីង កុលាបតើនៅមានប៉ុន្មាននាក់ទៀ!ដើម្បីតែប្រាក់ អ្វីក៏ហ៊ានធ្វើ អត់មានកិត្តិយសសេចក្ដីថ្លៃថ្នូរអី ផ្ទាល់ខ្លួនបន្តិចទេ!អញ្ចឹងទេតើបានជាពួកអ្នកមានអាចធ្វើអ្វីបានតាមចិត្ត!

នៅពេលនាងកំពុងសញ្ជឹងគិតសំឡេងស្ត្រីនោះបន្លឺតិចៗមកកាត់ផ្ដាច់ការរិះគិតរបស់នាង៖

ឱម៉ា!នាងសំណាងណាស់ណាកូនដែលកើតមកមានរូបសម្បត្តិស្អាតលើសគេ !អ្នកណាឃើញនាង ដែលថាមិនទន់ចិត្តនោះ!ផ្កានេះថ្លៃណាស់ណា!លោកប្រុសរាមទិញជូនកូនឯង គឺផ្ដល់កិត្តិយសមែនទែនហើយ!

ស្រី ស្រស់ស្ងៀមមិនចេញស្ដីតែនាងកំពុងគិតតែម្នាក់ឯងក្នុងចិត្ត៖

មីងកុលាប!មីងនិយាយយ៉ាងណាក៏និយាយទៅ!ហើយមីងកុំសង្ឃឹមរឿងខ្ញុំទៅរញ៉េរញ៉ៃជាមួយមនុស្ស ប្រុសម្នាក់នោះទៀត!

ឃើញនាងនៅស្ងៀមមីងកុលាបនិយាយបន្ថែម៖

កូនឯងព្រមជួយមីងលើកនេះ!មីងសន្យាថា....

មិនរង់ចាំអោយគាត់បញ្ចប់ប្រយោគទាន់ឡើយស្រី ស្អាតនៅចំពោះមុខដាក់ស្លាបព្រាចុះរួចនិយាយកាត់ភ្លាម៖

ខ្ញុំមិន អាចជួយអីមីងបានទេ!

នាងលើកក្រដាសមកផ្ជិតជូត មាត់នៅចំពោះមុខក្រសែភ្នែកភ័យ ព្រួយរបស់ស្ត្រីមេអរណ្ដើក។ គាត់ព្យាយាមនិយាយខ្សឹបៗ៖

ឱម៉ា!ជួយមីងចុងក្រោយទៅ!មីងស្បថចំពោះឯង!មីងឈប់ធ្វើអញ្ចឹងទៀតហើយ!មីងស្បថ!

នាងនិយាយកាត់ភ្លាមដោយមិនសម្លឹងមុខគាត់៖

មីងធ្វើ អីមិនធ្វើ អីអត់មានទាក់ទងអីនឹងខ្ញុំទេ!

ស្ត្រីនោះហាក់ដឹងច្បាស់ដល់ចិត្តថ្លើមនាង ថានាងក្រៅពីស្អាត ស្លូតបូត ថែមទាំងមានចិត្តសប្បុរសទៀតម្ល៉ោះហើយបានជាគាត់មិនដែលអស់សង្ឃឹមឡើយក្នុងការអង្វរករនាង៖

ឱម៉ា!ម្ដងនេះបើ នាងមិនជួយមីងទេ!មីងស្លាប់ហើយ!មីងស្លាប់មែន!

កេតឱម៉ាក្រេបទឹកមួយក្អឹករួចទើបឆ្លើយតបដោយងើបចេញពីគាត់ផង៖

ជឿខ្ញុំទៅ!អ្នកធំរបស់មីងគេមិនធ្វើ អីមីងទេ!បើគេធ្វើ គេអោយមីងចេញមកបានយ៉ាងម៉េចកើតទៅ?

ស្ត្រីនោះនៅតែមិនបោះបង់ចោលការព្យាយាមពន្យល់នាង៖

គេលែងមីងចេញមកព្រោះគេយល់មុខឯងហ្នឹងហើយ!

ភាគទី៦

ឱម៉ាឈ្ងោកមុខ។នាងសើចស្ងួត៖

មីងគិតថាខ្ញុំ ជាស្អីដែលគេត្រូវយល់មុខ?មីងមើលចុះ?គេដាក់អង្គរក្សពីរ នាក់នៅឆ្លេឆ្លាម៉ុំនេះ ខ្ញុំខ្លួនឯងមិន ដឹងមានរឿងថ្ងៃ ណាដែរផង ខ្ញុំអាចជួយអ្នកណាបាន!កូនសិស្សខ្ញុំមកសមតឡូវហើយ មីងអាណិតកុំអោយគេឃើញមីងនៅហ្នឹងនាំតែគេគិតអ៊ីចេះ អ៊ីចុះទេ!ចំណែករឿងអ្នកធំរបស់មីង មីងស្ងប់ចិត្តទៅ ខ្ញុំឃើញស្រីស្អាតមកច្រើនណាស់ គេប្រហែលជា កំពុងតែមានក្តីសុខជាមួយតារាណាម្នាក់ទៀតហើយ គេមិនបាននៅចងចាំជាប់ទោសអូសដំណើរមីងទេ មីងកុំបាច់ព្រួយ។

មីងកុលាបនៅតែព្យាយាម៖

លោកប្រុសរាមមិនមែនអញ្ចឹងទេឪម៉ា!នាងគិតចំណុចល្អៗរបស់លោកខ្លះផង!

បំណាច់លឺពាក្យនេះ នាងបែរជាចង់តែខឹងច្រឡោតភ្លាម។នាងចាប់ផ្ដើមមួហ្មងត្រង់ថាហេតុអ្វីស្ត្រីនេះចូលចិត្តនិយាយល្អអោយពួកមានអស់នោះខ្លាំងម្ល៉េះ។តែនេះជាចរិតឪម៉ា នៅពេលនាងខឹងគឺនាងកាន់តែស្ងប់ស្ងាត់និងលែងមាត់ក។

យល់ចិត្តនារី មីងកុលាបបន្ថឹមកបន្តភ្លាមដើម្បីកុំអោយនាងយល់ច្រឡំ៖

លោកប្រុសរាមមិនមែនជាបុរសល្មោភស្រីដូចនាងគិតទេកូន!

ទើសចិត្តពេកនាងតបមកវិញ៖

អញ្ចឹងគេមកទីនេះធ្វើអ្វី!ប្រុសៗមកកន្លែងនេះបើមិនមែនមកមើលស្រីៗតើមកធ្វើ អីវិញ?

ស្ត្រីនោះទីទើរ។គាត់មិនទាន់រក បានពាក្យឆ្លើយតប វិញទាន់ ផង កេតឪម៉ាបន្ថែម៖

គេវាយដល់ថ្នាក់ហ្នឹងហើយ នៅការពារគេទៀត!ប្រភេទមនុស្ស ល្អរបស់មីង សុទ្ធតែប្រភេទសំញែងអង្គរក្សហែហមឆ្វេងស្ដាំ !ការងារនៅស្រុកទេសមានមិននាំគ្នា ធ្វើ មកតាមមើលស្រីៗដល់ទីនេះ ទៀត!ខឹងបន្តិចបន្តួចប្រើដៃជើង បោកចានបោកកែវ!និយាយទៅ ពួកគេល្អៗដល់ហើយ!

ស្ត្រីនោះដូចជាទប់ចិត្តស្ដាប់គំនិតផ្អៀងលើហេតុផលតែ ម្ខាងរបស់នាង លែងបានគាត់ ក៏ដំឡើងសំឡេងតបតវិញ៖

តែគេមិនដែលហៅឯងទៅដេកទៀតទេមែនទេ!បើគេលោភស្រីដូចឯងនិយាយមែន គេអោយលុយឯងចាយរាល់ខែ អោយលុយឯងរាប់ពាន់មើលជំងឺប្អូន ហើយទុក ឯងអោយសោយសុខអញ្ចឹងហ្អី?

ឪម៉ាសម្លឹងគាត់វិញដោយកំហឹង។នាងចង់តបតវិញភ្លាមដែរថានាងមិនដែលទទួលប្រាក់ខែអីនោះទេ តែនាងទប់មកវិញព្រោះរំពេចនោះនាងស្រាប់តែនឹកឆ្ងល់។មែន!ចុះបើនាងមានចំណុចខ្សោយក្នុងដៃគេអញ្ចឹង ម៉េចក៏រាមនរិន្ទមិនដែលមករកនាងទៀត?គេចំណាយលុយលើនាងចោលដើម្បីអ្វី?

ស្ត្រីមេអណ្ដើកពន្យល់ពីលើភាពងឿងឆ្ងល់របស់នាង៖

ព្រោះលោកជាមនុស្សមានមេត្តា!លោកមិនមែនដូចប្រុសៗផ្សេងៗទេ!

នាងនិយាយកាត់អោយរួចតែពីមាត់៖

គេជាអ្នកធំ គេមានស្រីស្អាតច្រើនរាប់មិនអស់ គេមានអំណាចទឹកលុយរបស់គេ បានជាគេគ្មានពេល!

ដល់ពេលមីងកុលាបសើចឃឹកៗក្នុងបំពង់កចំអកអោយចម្លើយរបស់នាងវិញម្តង។គាត់និយាយ៖

គ្មានមនុស្ស ប្រុសណាម្នាក់ដែលថាគ្មានពេលសម្រាប់រឿងស្រីញីទេកេតឱម៉ា!វាគ្រាន់តែគេចង់រឺមិនចង់តែប៉ុណ្ណឹងឯង។

នារីនៅតែមានះ៖

អញ្ចឹងមានតែខ្ញុំមិន ស្អាតដូចស្រីផ្សេងៗទៀតរបស់គេ!

អ្នកស្រីកុលាបបង្ហាញទឹកមុខហួសចិត្ត។

កូនអើយកូនស្រី!តើឯងកើតអីបានជាក្លាយជាមានះទទឹងទទែង!ម៉េចមិនគិតអោយល្អៗផងអ្ហា!មានគំនុំនឹងគ្នាតាំងពីពេលណាមក?មីងនិយាយប៉ុណ្ណឹងហើយឯងនៅមិន ជឿទៀត?មីងសួរឯង!ថ្ងៃនេះមីងត្រូវបកស្រាយអោយអស់!បើមីងមិនទុកចិត្ត ថាលោកប្រុសរាមជាមនុស្សល្អ មីងមានរឿងអី ហ៊ាននែណនាំឯងអោយអ្នកប្រុសសិទ្ធិគុណ!?គឺវាមកតែពីមីងដឹងច្បាស់ពីចរិតលោកប្រុសរាមថាលោកមិនធ្វើបាបស្រីៗទេ !គឺលោកមិនបង្ខំឯងទៀតទេ !មីងដឹងច្បាស់!

ឱម៉ាភ្នែកសញ្ជឹងគិត។រឺមួយពិតមែន?រឺមួយម្នាក់នោះសរសៃប្រសាទដល់ថ្នាក់ចិញ្ចឹមស្រីហើយអត់ហៅទៅជួប ?មានមនុស្សចិត្តសប្បុរសដល់ថ្នាក់ហ្នឹងដែរ?ទាល់តែឆ្កួតបានជឿ។នៅពេលនាងគិតដល់ត្រង់ណេះនាងសឹងថាពេបមាត់ដាក់ស្ត្រីនោះ។ប៉ុន្តែនាងគិតភ្លាមដល់ទឡ្ហីករណ៍មួយផ្សេងរបស់គាត់។បើមិនមែនអញ្ចឹងម៉េចគាត់ហ៊ានលក់នាងបន្តអោយអ្នកផ្សេងដោយមិនក្រែងចិត្តរាមនរិន្ទពិសេសហ៊ានទទួលលុយគេមកដោយមិនអោយនាងដឹងទៀត?រឺមួយគេពិតជាមានស្រីច្រើនដល់ថ្នាក់គ្មានពេលជួបអ្នកណាអោយលើសពីម្តងមែន?រឺមួយគេមាននារីសំណព្វហើយ?រឺមួយ...

គិតចុះគិតឡើងកាន់តែឈឺក្បាល នាងសម្រេចថាលែងខ្វល់។ចំពោះមុខគឺធ្វើយ៉ាងណាអោយស្ត្រីល្មោភ ប្រាក់នេះចាកចេញកាន់តែឆាប់កាន់តែល្អនឹងអាលនាងបានយកពេលស្រមៃទៅរកម្ចាស់ផើងផ្កា Saffronល្អជាង។

កល្យាណីក្រោកទៅទាញបិទបង្អួចវិញ ហើយហៀបនឹងហារបណ្តេញស្ត្រីនោះជាលើកទី២ទៅ ហើយស្រាប់តែលឺស្នូរសារទូរស័ព្ទរបស់គាត់លាន់ឡើង។នាងសម្លឹងទៅ គាត់ដែលចុចទទួលដោយដៃញ័រទទ្រើក។

បន្ទាប់មកគាត់ងើបមុខមករកនាងវិញដោយភាពភ័យព្រួចសម្តែងចេញតាមក្រសែភ្នែកទាំងគូរ។នាងឃើញគាត់មានអាការៈប្លែកក៏សួរវិញភ្លាម៖

មីងមានរឿងអីហ្នឹង?

ស្ត្រីនោះឆ្លើយដាច់ៗ៖

លោកប្រុសរាម!

ធីតាយើងសម្លឹងទៅទូរស័ព្ទដែលកំពុងត្រូវបានហុចមកអោយនាង។តួអក្សរត្រង់ភ្លឹងខ្លីតែមានន័យច្បាស់កំពុងអណ្តែតឡើងក្នុងក្រសែភ្នែកនាងទាំងគូ៖

ណាត់កេតឌីម៉ា!ថ្ងៃស្អែកម៉ោង៩យប់ ជួបគ្នានៅAmandari

នាងដៀងភ្នែកសម្លឹងទៅរកស្ត្រីនោះដែលកំពុងស្ថិតនៅក្នុងស្ថានភាពឆ្លេឆ្លា។ឌីម៉ាសើចចុងមាត់របៀបចំអកហើយហុចទូរស័ព្ទទៅសងគាត់វិញរួមជាមួយប្រយោគជាន់កែង៖

ក្រែងថាលោកប្រុសរបស់មីងមិនមែនល្មោភ ស្រីនិងមិនចូលចិត្តបង្ខំស្រីៗទេអ្ហី?

## វគ្គទី៣

## មនុស្សជំនិត

ពពុះប៊ីយែររលាយខ្សុល បន្សល់នូវក្រសែភ្នែកមមីជាសញ្ញារិះគិតនៃបុរសសម្បុរ ស្រអែមដែលជានិច្ចជា កាលមានស្នាមញញឹមប៉ប្រិមលើបបូរមាត់។

មនុស្សជំនិតដែលដើរតាមរាមនរិន្ទជាច្រើនឆ្នាំមកហើយ រឿងអីមិនដឹងថាថៅហ្វាយខ្លួនស៊ើច ប៉ុន្តែក្នុងចិត្តមិនមែនប្រាកដថាគេកំពុងរីករាយនោះ។

គេប្រញាប់រៀបរាប់ប្រាប់បន្តះ

លោកប្រុសរាម!យប់មិញម្ចាស់ហាងវត្ថុបុរាណធំបង្អស់នៅបាលីអះអាងថា បដិមានោះត្រូវបញ្ជូនទៅដល់ ខេត្តPapuaតាំងពីឆ្នាំ១៩៨៩ហើយវាក៏បាត់ដំណឹងតាំងពីពេលនោះមក!

រាមនរិន្ទនិយាយដោយសម្លឹងផ្តោតទៅពពុះប៊ីយែរះ

គេមានខ្សែរយៈទេរឿន?

"រឿន"វ័យ៣៥ឆ្នាំជាមនុស្សជំនិតតាំងពីកុមារ របស់បុត្រានៃត្រកូលអ្នកនយោបាយល្បីឈ្មោះ អោនមកខ្សឹបក្បែរត្រចៀកនាយថៅហ្វាយះ

១០លានRupiahs (១ម៉ឺនដុល្លារ)ទាន!

Rupiahគឺជារូបិយប័ណ្ណឥណ្ឌូណេស៊ីដែលមានតម្លៃក្នុងប្រហាក់ប្រហែលនឹង១ម៉ឺនRupiah ក្នុងមួយ ដុល្លារអាមេរិក។រាមនរិន្ទដាក់កែវ ប៊ីយែរចុះព្រោះគេយល់ថាប្រាក់១ម៉ឺនដុល្លារក្នុង ការទិញបានត្រឹមតែព័ត៌មានខ្សែរយៈ ជាតម្លៃមួយថ្លៃហួស ប៉ុន្តែ វានៅតែមិនអាចប្រៀបស្មើទៅ នឹងតម្លៃមហិមានៃវត្ថុដែលខ្លួនកំពុងស្វែងរកបានទេ។នេះអាចថាជាសរសៃអំបោះដ៏ សំខាន់ទោះបីវាតូចប៉ុណ្ណាក៏ដោយដូច្នេះគេត្រូវតែងក់ក្បាលផ្ងក់ៗះ

អោយគេធ្វើការទៅ!

នាយរឿនងក់ក្បាលផ្ងក់ៗរបៀបយល់ ការហើយ បែរក្រោយបម្រុងចាកចេញទៅតែត្រូវ ថៅហ្វាយប្រុសហៅឃាត់មកវិញះ

រឿន!

នៅពេលមនុស្សក្រោមបង្គាប់ងាកមកវិញរង់ចាំបទបញ្ជា រាមនរិន្ទសម្លឹងមុខគេចំហើយបញ្ចប់ ប្រយោគះ

ខ្ញុំត្រូវការឆាប់!ហើយស្ងាត់!

នាយរឿនមិនទាន់ឆ្លើយ ថាយ៉ាងណាផង ស្រាប់តែស្នូរប៉ះ ទ្វារបន្ទប់ក្តុកធ្វើអាយអ្នកទាំងទ្វេ ងាកទៅរកប្រភពនៃសូរសម្លេង។នាយរឿនពោលសួរដោយរហ័ស៖

អ្នកណា ហ្នឹង!

ស្នូរគោះទ្វារលាន់ឡើងសារជាថ្មី រួចទើបលឺសូរសំឡេងតបមកវិញ៖

គឺខ្ញុំទានប្រុស!

រាមនរិន្ទងាកមុខចេញតែគេលើកដៃជាសញ្ញាអោយរឿនទៅបើកទ្វារបន្ទប់។បុរសទាបស បង្ហាញខ្លួនជាមួយទឹកមុខតក់ក្រហល់។គេអោនគួរសមដាក់រឿនរួចទើបដើរហួសមករក ថៅហ្វាយ ធំចំពេលរាមនរិន្ទពោលសួរដោយមិនងាកមុខ៖

ម៉េចហើយBird?

បុរសខ្មែរដែលមានឈ្មោះបរទេសរលះរលាំងឆ្លើយតបទៅរកនាយថៅហ្វាយ៖

យាយនោះបោកប្រាស់យកលុយថៅហ្វាយតែម្នាក់ឯង ចំណែកគ្រូម៉ូដែលនោះមិនបានដឹង រឿងអីទាំងអស់ទាន!

ភ្នែកទាំងគូរបស់បុរសមានអំណាចដែលបិទព្រឹមៗរង់ចាំទទួលសេចក្តីរាយការណ៍ ស្រាប់តែបើក ខ្វាកមកវិញនិមិត្តតែលឺប្រយោគនេះ។នាយរឿនស្ទុះចូលមកសង្ហើញសួរក្នុងពេលដឹងថាព័ត៌មាននេះបានធ្វើអាយថៅហ្វាយភ្ញាក់ផ្អើល៖

Bird?ឯងចង់ថាយាយកុលាបហ្នឹងស៊ីដាច់លុយម្នាក់ឯង?

នាយBirdតបវិញរអិលព្រិល៖

បងរឿន!មិនត្រឹមស៊ីដាច់ទេតែ ស្រីបង្ហាញម៉ូតនោះគឺអត់ ដឹងរឿងតែម្តង!យាយ នោះបោកប្រាស់ទាំងសងខាងហើយនាំនាងមកកំដរអ្នកប្រុសដូរជាមួយលុយជំពាក់ បន្ទាប់មកប្រាប់អ្នកប្រុសថា នាងស្រលាញ់ចង់សងគុណហើយអ្នកប្រុសក៏ចាយ លុយទៅទំនុកបម្រុងរាល់ ខែ!តែនាងមិនដែលទទួល លុយទេព្រោះនាងគិតថាទូទាត់គ្នាចប់ហើយ!

រាមនរិន្ទបង្ហាញភាពអស់សំណើចលើផ្ទៃមុខក្នុងពេលនាយរឿនហាក់ផ្ទុះ កំហឹង។គេបន្លឺមួយៗមុនថៅហ្វាយទៅទៀត៖

យាយនេះមិនចោលពុតសោះ!

បុរសទើបតែមកដល់នោះបន្លឺបន្ត៖

គាត់ជំពាក់លុយគេច្រើនណាស់!លេងល្បែងនៅកាស៊ីណូ ថៃផងវៀតណាម ផង ហើយបាន ទាក់ទងធ្វើឈ្មួញកណ្តាលរឿងតូកុនស្រីៗច្រើនមកហើយ!ឥឡូវកំពុងស្ថិតក្នុងគោលដៅឃ្លាំមើលរបស់ប៉ូលិសខាងជួញដូរ!

នាយរឿងនិយាយដោយកំហឹង៖

ចាំបញ្ជូនគាត់ទៅអោយគេអោយចប់រឿងតែម្តងទៅ!

នាយBirdពោលសួរខ្សឹបៗ៖

ចុះរឿងដែលអោយនាងមកជួបអ្នកប្រុសនៅAmandariយប់នេះ?

រឿនមិន អាចឆ្លើយ បានទេទើបគេងាកទៅរក រាមនរិន្ទដែលកំពុងឈោងដៃទៅចុចបើក ទូរទស្សន៍មើល។ឃើញអង្គរក្សហាក់រង់ចាំចម្លើយ រាមនរិន្ទញញឹមពោលសួរមកកាន់បរិវារទាំងទ្វេ៖

គិតថាកេតឌីម៉ាព្រមមកទេ?

នាយBirdមិនឆ្លើយបែរជារៀបរាប់បន្ត៖

យប់បើមិញយាយ ហ្នឹងតាមអង្វរនាងដល់កន្លែងតែម្តង!ឃើញចូលជួបគ្នាក្នុងបន្ទប់យូរណាស់!

នាយរឿននិយាយកាត់ភ្លាម៖

បើនាងចង់ជួយលាក់ទោសយាយហ្នឹងមានតែមករកអ្នកប្រុសតាមការណាត់ជួបហ្នឹងហើយ! រាមនរិន្ទ ញញឹមមើលមុខបរិវារួចសួរបន្ត៖

មានន័យថាស្រីបង្ហាញ ម៉ូតហ្នឹងដឹងរឿងបោកប្រាស់នេះអស់ហើយ?

ទាំងនាយរឿននិងនាយBirdងក់ក្បាល។ រាមនរិន្ទពោលបន្ត៖

អញ្ចឹងបើគេព្រមមក មានន័យថាគេកំពុងរួមដៃជួយកុហកអោយមីងកុលាប ?

នាយវឿនងាកមើលមុខនាយប៊ីត។ភ្លាមនោះនាយវឿននិយាយកាត់ ផ្ទួង៖

អ្នកប្រុស ពួកស្រីៗក្នុងសិល្បៈនេះមានល្បិចច្រើនណាស់!កុំអោយមកក្បែរខ្លួនទៀត ចាំខ្ញុំទៅរំសាយការ ណាត់ហើយនាំស្រីចាស់នោះចាប់បញ្ជូនទៅអោយប៉ូលិសស្រុកខ្មែរ!

រាមនរិន្ទលើកកែវប៊ីយែរក្រេប។ក្នុងពេលនាយBridពោលប្រកែក៖

តែស្រីនោះអត់ដឹងរឿងអីទេ!ហើយ នាងស្អាតណាស់ ប្រុសៗតាមដល់ហើយ!

នាយវឿនពេបមាត់និយាយបដិសេធ៖

ស្អាតបានការអី!មនុស្សស្រីកាន់តែស្អាតកាន់តែពិសពុល!នាំតែអំពល់ទុក្ខទេ !អ្នកប្រុសមានការងារធំត្រូវធ្វើ!

នាយBirdបានឱកាសសួរវិញភ្លាម៖

ការងារធំអីទៅ?

នាយវឿនសម្លក់ត្និលដូចជាមិនពេញចិត្តនឹងសំនួរនេះ។គេហៀបនឹងហារសម្លុតដៃគូទៅ ហើយតែសំឡេង រាមនរិន្ទលាន់លឺ មក៖

ខ្ញុំចង់ជួបកេតឌីម៉ា!ចង់ដឹងថានាងនឹងធ្វើម៉េចតឡូវជាមួយខ្ញុំ!

នាយវឿនហួសចិត្តដែលនៅសុខៗចៅហ្វាយ ខ្លួនបែរជាប្តូរទម្លាប់មកចង់លេងសើចក្នុងកាលៈទេសៈដែលបេសកកម្មដ៏ធំមួយកំពុងហៀបនឹងចាប់ផ្តើមនេះ។ក្នុងនាមមនុស្សជំនិត គេនៅតែព្យាយាមបញ្ជាប់កាតព្វកិច្ចរបស់ខ្លួនមួយគឺដាស់តឿន។គេនិយាយ៖

អ្នកប្រុស ឈប់រវល់នឹងស្រីនោះទៅ!

ភាគទី៧

រាមនរិន្ទញញឹមសម្លឹងមកមនុស្ស ក្រោមបង្គាប់ដោយទឹកមុខចំអន់៖

ស្រីហ្នឹងមាត់រឹងល្មមអោយនឹកដែរហ្នឹងវឿន!ចង់មើលមុខនាងលេងមើល៍ ចូលដៃជួយកុហកអោយមីងកុលាបម៉េចខ្លះ!?

នាយវឿនដកដង្ហើមធំនៅពេលដឹងថាចៅហ្វាយកំពុងដំអក់មុខដំណាក់ស្រី ស្រស់។គេមិនហ៊ាននិយាយអីទៀតទេ គ្រាន់តែលួចគិតក្នុងចិត្តស្ងាត់ៗថា យ៉ាងយូរ២ថ្ងៃទៀតចៅហ្វាយស្រស់ សង្ហានេះនឹងចាកចេញទៅកាន់កន្លែងផ្សេងហើយ បើលោកចង់សប្បាយ តាមដំណើរចុះ។

ចុះយាយប៉ុនោះ?(សំឡេង នាយBirdសួរ វិញ)

រាមនរិន្ទមិនឆ្លើយទេគឺទុកអោយនាយវឿនឆ្លើយជំនួស។

ឯងល្ងង់ណាស់អាBird!បើអ្នកប្រុសចង់មើលគេលេងល្ខោនហើយ ឯងចង់វាយស្នៅបង្អើលពស់អោយគេដឹងខ្លួនហ្អី?

នាយBridឈ្ងោកមុខរបៀបដឹងកំហុសក្នុងពេលនាយវឿនកំពុងស្នូគស្នាញ។បេសកកម្មស្វែងរកបដិមាអាថ៌កំបាំងកំពុងស្ថិតនៅកៀកនឹងចុង ច្រមុះ ហើយស្ថានភាពគ្រោះថ្នាក់យ៉ាងណាក៏នៅមិនទាន់មានអ្នកណាអាចស្មានដឹងមុនទេ ហេតុអ្វីក៏ចៅហ្វាយក្មេងនៅមានចិត្តលលេងនឹងទង បុប្ផាក្រៅរបងទៀត។គិតយ៉ាងណាបានត្រឹមគិត តែគេមិនហ៊ានដាស់តឿនអីអោយលើសពីម្តងដែរព្រោះគេក៏ដឹងដែរថារាមនរិន្ទមិនមែនមនុស្សអត់ បញ្ញាឯណា។

នៅប្រមាណ ជា៣០០មពីទីនោះរលកបោកច្រាំងប្រាវៗ នាំមកជាមួយនូវកម្លាំងវាយោស្រស់បរិសុទ្ធនាពេលព្រឹកព្រហាម ផាត់លំអបុប្ផាពី រទងដែលកំពុងក្រេបភេសជ្ជៈបន្ទាប់ពីហាត់រត់កម្តៅកាយតាមបណ្តោយឆ្នេរសក្បុស។

ហើយចុះឯងទៅជួបគេទេឱម៉ា?(ស្រី ស្អាតសម្បុរ ស្រអែមស្រស់សួរមកកាន់កេតឱម៉ាដែលកំពុងលើកកែវទឹកក្រូចស្រស់ក្រេបតិចៗ)

កេតឱម៉ាឆ្លើយតបដោយកាយវិការមិន ខ្វល់៖

លំអងឯងគិតថា ខ្ញុំទៅជួប គេអញ្ចឹងអ្វី?

នៅពេលឃើញមិត្តភ័ក្តិនៅតែសម្លឹងមកដោយកែវភ្នែកព្រួយបារម្ភ ឱម៉ាដំឡើងចិញ្ចើមរបៀបងឿងឆ្ងល់៖

នែ៎នាង!ឯងម្នាក់ទៀតហើយអ្វី?ឯងគិតចង់អោយយើងទៅជួបប្រុសម្នាក់ហ្នឹងមែនអ្វី?

លំអងជាមិត្ត រួមក្រុមជាមួយឌីម៉ានិយាយឡើងភ្លាមៈ

យើងមិនដឹងទេ!តែ តែ

តែស្អីទៅ?(ឌីម៉ាសួរវិញបណ្ដើរលើកកន្សែងជូតផ្ដិតញើសដែលហូរសស្រាក់បន្ទាប់ពីការហាត់ប្រាណក្រោមពន្លឺព្រះទិនករព្រហាមស្រាង)

លំអងគិតបន្ដិចទើបនិយាយទាំងទឹកមុខភ័យព្រួចៈ

គ្នាខ្លាចឯងមានរឿងរ៉ាវទៀតហ្នឹងណា!

ឌីម៉ាបង្ហាញភាពខ្វាយខ្វល់។នាងតបសំណួរវិញភ្លាមៈ

តែយើងមិនបានបង្ករឿងទេ!មីងកុលាបគាត់ជាអ្នកយកលុយគេ គេ គួរតែ ដឹងរឿងពេលនេះតែម្ដងទៅ អោយវាជ្រះស្រឡះ!យើង ក៏មិនចង់ពាក់ព័ន្ធអីទាំងអស់!

លំអងឈ្ងោកមុខដោយទឹកមុខខ្វល់ខ្វាយ។ហាក់យល់ចិត្តមិត្ត កេតឌីម៉ានិយាយទម្លាក់សំឡេងៈ

លំអង!គ្នាសូមទោស!គ្នាមួម៉ៅបានជានិយាយលឺៗជាមួយឯង!

លំអងគ្រវីក្បាលៈ

យើងមិនខ្វល់រឿងហ្នឹងទេ!យើងគ្រាន់តែគិតថា ហេតុការណ៍វាមិនទំនងងាយដោះស្រាយដូចឯងគិត!

ឌីម៉ានៅស្ងៀម។នាងពាក់កន្សែងជូតញើសទៅលើស្មាចោមព័ទ្ធជុំវិញ សាច់ស្ដើងសគួរជាទីប្រតិព័ទ្ធទាំងទឹកមុខទើសទាល់។តាមពិតខ្លួននាងផ្ទាល់ក៏យល់ថាតប់ប្រមល់ដែរ តែនាងបានជាសម្រេចចិត្តថាគេចវេះមិនប្រឈមមុខព្រោះនាងមានជំនឿចិត្តថាខ្លួនមិនបានធ្វើខុសគ្មានរឿង អ្វីត្រូវខ្លាចនោះទេ។តែនៅពេលមិត្តភ័ក្ដិរំលឹកដូច្នេះហេតុការណ៍វាយដំលើអ្នកស្រីកុលាបកាលពីល្ងាច ម្សិលបានលេចធ្លោសារជាថ្មីក្នុងអារម្មណ៍របស់ស្រស់ស្រី។ឌីម៉ានិយាយដោយជ្រប់មុខៈ

យើងដឹងហើយលំអង !ដោយសារឯងបានជួយយើងពេលដែលប្អូនយើងឈឺ គឺឯងនាំយើងទៅរកគាត់គាត់ក៏នាំយើងទៅជួបប្រុសនោះ!យើងជំពាក់គុណឯង ឯងក៏ជំពាក់គាត់ គាត់ក៏

យកលុយប្រុសនោះ រឿងរ៉ាវគឺវាបន្ត កន្ទុយគ្នា!ឯងចិត្តមិនដាច់ពីមីងកុលាប គ្នាក៏អញ្ចឹងដែរ! តែ តែយើងគ្មានសេចក្តីក្លាហានអីទៅជួយដោះស្រាយគាត់ទេ!គាត់ចេះទៅបោកប្រាស់គេអញ្ចឹងកើត ហើយឥឡូវវ័ណ្ឌក អោយគ្នាទៅរង !ចុះបើលោតែគេដឹងរឿង គេខឹងទាំងគ្នាម្នាក់ទៀត?

លំអងងើបមុខសម្លឹងកេតឌីម៉ា។នាងនៅស្ងៀមស្ងាត់មួយស្របក់ទើបហើបមាត់និយាយៈ

ឌីម៉ា!ឯងជួយគាត់ជាចុងក្រោយទៅ!

ឌីម៉ារភ្នែកសម្លឹងមិត្ត។នាងព្រិចភ្នែកដោយង៉េមង៉ាម។នាងដណ្ដឹងសួរខ្លួនឯងស្ងាត់ៗក្នុងចិត្តៈ

លំអងអើយលំអង!ឯងដឹងថា កន្លែងនោះស្លាប់ហើយ នៅអោយមិត្តទៅទៀតមែនទេ?

ទោះនាងមិននិយាយចេញមក តែទឹកមុខគួរអោយអាណិតនោះបានបង្ហាញន័យអោយលំអងយល់ជាស្រេចហើយថាឌីម៉ាពិតជាកំពុងខ្លាចមែន។នាងសួរតិចៗៈ

ឯងមានសង្សារហើយមែនទេ?

សំនួរនាងធ្វើអាយឌីម៉ាចាប់ផ្តើមជ្រួលច្របល់។លំអងជាមិត្ត ល្អតាំងពីយូរ ណាស់មកហើយ មិនសមថាមានរឿង អ្វីលាក់បាំងនឹងនាងទេ ពិសេសសូម្បីពេល ប្អូននាងឈឺធ្ងន់គឺមានតែលំអងម្នាក់គត់ដែលបានចេញមុខជួយនាង។តែបើនិយាយពីម្ចាស់ផ្កាSaffronដែលនាងទើបតែស្គាល់បាន៤៥ថ្ងៃ គឺនាងគ្មានសិទ្ធិបង្ហើបរឿង នេះប្រាប់អ្នកណាជាដាច់ខាត។នាងមិនចង់និយាយកុហកមនុស្សដែលនាងបានហៅថាមិត្តតាំងពីទើប បោះជំហានចូលសិល្បៈទេ តែនាងត្រូវតែបង្ខំចិត្ត។

មានឯណា!(ឌីម៉ាគ្រវីក្បាលបដិសេធ)

លំអងងក់ក្បាលផ្ងក់ៗ។បន្ទាប់មកនាងដាច់ចិត្តនិយាយៈ

អញ្ចឹង!ទៅម្តងទៀតទៅឌីម៉ា!

ឌីម៉ាឃើញភាព ប្រាកដប្រជាលេចឡើងភ្លែតនៅចំពោះមិត្ត នារីដែលនាងធ្លាប់កម្សត់កម្រជាមួយហើយក៏ដឹងដែរថាលំអងមិនបាននិយាយលេងទេ នាងមានភាពចាំបាច់ក្នុងការសំណូមពរដូច្នេះ ប្រហែលដោយសារនាងអាណិតអ្នកស្រីកុលាប។

អ្នកគ្រូបង្ហាញមុំតនាងបន្ទន់ខ្លួនល្វើយដោយអស់រលើងកម្លាំងកំហែង។នាងនិយាយតិចៗស្ទើរស្តាប់មិនលឺ៖

លំអង!ឯងចេះអាណិតគេ តែឯងមិនអាណិតមិត្ត ភក្តិខ្លះទេ?

លំអងលើកដៃផាត់ សក់មិត្តសម្លាញ់ដែលកំពុងជ្រប់មុខយ៉ាងស្រងូត។នាងនិយាយតបវិញ៖

ឪម៉ា!គឺយើងគិតឯង បានជាយើងអោយយោបល់អញ្ចឹង!

នៅពេលឪម៉ាសម្លឹងមកដោយក្រសែភ្នែកមូលក្លំហាក់កំពុងស្តាប់ដើម្បីបញ្ចប់ចម្ងល់ លំអងនិយាយបន្ត៖

បើឯងថាចង់ដោះស្រាយអោយចប់ ឯងមិន អាចអោយរឿងចប់ទៅដោយគេចមុខអញ្ចឹងទេ! ហោចណាស់ក៏ឯងត្រូវនិយាយជាមួយ គេអោយច្បាស់ដែរ!

ឪម៉ាបង្ហាញភាពស្លេកស្លាំងលើផ្ទៃមុខ។

លំអង!ចុះម៉េចក៏ឯងដឹងថា គេនឹងអត់ធ្វើបាបគ្នា!

លំអងកៀកស្មាឪម៉ារួចទាញនាងអោយក្រោកឈរពីឆ្នេរ។

បើគេកម្រោលដូចឯងគិត តាំងពីល្ងាចម្សិលគេលែងឯងចេញមកធ្វើ អី?មនុស្សប្រុស បើសូម្បីតែតណ្ហាខ្លួនក៏យកឈ្នះបាន គេមិនមែនទៅលើកដៃធ្វើបាបស្រីទន់ខ្សោយម្នាក់កើតទេឪម៉ា! សំខាន់ត្រូវប្រាកដថាយើងគ្មានកំហុស ហើយពន្យល់គេអោយច្បាស់ទៅ!

ឪម៉ានៅតែមិនអស់ចិត្ត នាងសួរសង្ស័យវិញ៖

បើគេមិនគិតផ្តេសផ្តាសល្ងាច នេះគេណាត់យើងទៅធ្វើអី?មួយទៀត បើយើងនិយាយការពិតទៅ គេអាចលើកលែងអោយមីងកុលាប ដែរ?

លំអងដកដង្ហើមធំ៖

សាកមើលសិនទៅ!គឺដូចតែគ្នាទេ បើគេចង់ធ្វើបាបមីងកុលាបមែន គេមិនចាំដល់ថ្ងៃនេះទេ! និយាយអញ្ចឹង គេណាត់ឯងទៅកន្លែងណា?

ឪម៉ាដកដង្ហើមធំវិញម្តង៖

គេផ្ញើសារមកមីងកុលាប ថាអោយនាំគ្នាទៅជួបនៅកន្លែងឈ្មោះថាAmandari!អត់ស្គាល់ដែរ ហ្នឹងតែដូចជាធ្លាប់លឺពាក្យ ហ្នឹង!

លំអងនិយាយតវិញភ្លាមៈ

កន្លែងស្នាក់នៅរបស់ពួកអ្នកមាន!ជាកន្លែងលំដាប់កំពូលនៅបាលីនេះហើយ!

ឌីម៉ាធ្វើមុខអន់ចិត្តៈ

ចាំបាច់ឯងនិយាយបង្វែងបង្វៀនថាកន្លែងស្នាក់នៅអី!មិនថាសណ្ឋាគារតែម្តងទៅ?

លំអងដឹងថាមិត្តកម្សត់របស់នាងកំពុងគិតអីហើយម្ល៉ោះហើយនាងចាំបាច់ត្រូវតែពោលលួង ភ្លាមៈ

ឌីម៉ា!អ្នកទៅសណ្ឋាគារទាំងអស់មិនមែនសុទ្ធតែទៅគេងជាមួយគេទេមែនទេ?វាជាresort ទេ !ជាកន្លែងស្នាក់នៅលាយឡំនឹងធម្មជាតិ!គិតទៅគេRomanticណាស់ដែរដែលរើសកន្លែង ហ្នឹងណាត់ឯងទៅជួប ណ៎ាស្រីស្អាត!

ឌីម៉ាធ្វើទឹកមុខអស់កម្លាំងងាកចេញទៅម្ខាងៈ

មើលទៅឯងដូចជាត្រូវចិត្តណាស់អញ្ចឹងជួយទៅជំនួសតែម្តងទៅអោយវាចប់រឿង!

លំអងដឹងថាត្រូវមិត្ត ភក្តិលលេងហើយនាងធ្វើជាលលេងតបវិញដែរៈ

មានអី!បានទៅដល់ហើយជួយនិយាយណាត់គេអោយគ្នាផង ថាមានស្រី ស្អាតម្នាក់ទៀតនៅ កិន្នរីហ្វេស្ស៊ិនចង់មានឱកាសបានទៅក្រេបច័ន្ទទឹកឃ្មុំនៅហ្នឹងដែរ!

ឌីម៉ាក្តាប់មាត់ងាកសម្លក់មិត្តៈ

លេបសម្តីខ្លួនឯងភ្លាមទៅហើយ?មិញនេះអ្នកណាថា អ្នកទៅសណ្ឋាគារទាំងអស់មិនមែន សុទ្ធតែទៅ គេងជាមួយនោះ?

លំអងញាក់ចិញ្ចើមញញឹម។ឃើញឌីម៉ាជ្រប់មុខដោយស្មុគស្មាញ នាងសម្រួលទឹកសម្លេង ពន្យល់ៈ

នៃAmandariជាភាសាសំស្ក្រឹតប្រែមកថា សន្តិភាពផ្លូវចិត្ត !ឯងមិនបាច់គិតពីរឿងអាក្រក់ៗទេ!អ្នកដែលណាត់ឯងទៅហ្នឹង គេកំពុងមានសន្តិភាពផ្លូវចិត្តជាមួយឯងច្បាស់លាស់!

ឱម៉ានិយាយបន្លប់ភាពភ័យ បារម្ភ៖

ចេះបាលីសំស្ក្រឹតទៀតលំអង?

ក្នុងពេលនារីជាមិត្តប្រឹងសើចបន្លប់ឱម៉ាលួចគិតស្ងាត់ៗក្នុងចិត្ត៖

ឯងចេះតែសើចចេញហើយលំអង!តែបើឯងជាខ្ញុំវិញ ឯងក៏គ្មានថ្ងៃទៅជួបប្រុសនោះដូចគ្នាដែរ។

តើមិត្តអ្នកអានយល់ថា កេតឱម៉ាគួរទៅជួបរាមនរិន្ទតាម ការណាត់ដែរឬទេ? ចុចអានភាគទី២